

# សិទ្ធិមនុស្ស និង ពន្ធនាគារកម្ពុជា:

# របាយការណ៍ ស្ដីពី សុខភាព ឆ្នាំ ២០០១


## លីកាដូ

# មាតិការ


I- អារម្ភកថា ---------- ៣

II- បុព្វកថា ---------- ៤

III- សេចក្តីសង្ខេប ---------- ៥

IV- ចំនួនអ្នកជំងឺ ---------- ៨

V- លទ្ធភាពក្នុងការថែទាំសុខភាព ---------- ១០

VI- រោគវិនិច្ឆ័យចំនួន ២០ ប្រភេទ ដែលច្រើនបំផុតក្នុងឆ្នាំ ២០០១ ---------- ១៣

VII- កំណត់សំគាល់ចំពោះស្ថិតិ ---------- ១៤

VIII- អនាម័យ និង ជំងឺឆ្លង ---------- ១៤

IX- បញ្ហាកង្វះម្ហូបអាហារៈ ជំងឺស្លឹកនៅក្នុងពន្ធនាគារ ---------- ១៩

X- កង្វះទឹកស្អាត ---------- ២១

XI- ស្ត្រីជាប់ពន្ធនាគារៈ បញ្ហាសម្ភព និង រោគស្ត្រី ---------- ២២

XII- ការរំលោភផ្លូវភេទក្នុងពន្ធនាគារ ---------- ២៥

XIII- បុគ្គលិកពន្ធនាគារ ---------- ២៧

XIV- សេចក្តីសន្និដ្ឋាន ---------- ២៧

XV- អនុសាសន៍សង្ខេប ---------- ២៧

ឧបសម្ព័ន្ធ កៈ ស្ថិតិរោគវិនិច្ឆ័យឆ្នាំ ២០០១ ---------- ២៩

ឧបសម្ព័ន្ធ ខៈ ឯកសារសិទ្ធិមនុស្សអន្តរជាតិដែលជាប់ទាក់ទង ---------- ៣៤



ទំនាក់ទំនង : លោកស្រី វេជ្ជ. **ពុង ឈីវកេក** ប្រធានអង្គការ លីកាដូ

សរសេរដោយ : ការិយាល័យពេទ្យ

អាសយដ្ឋាន : ផ្ទះលេខ១០៣ ផ្លូវ៩៧ សង្កាត់បឹងត្របែក ខណ្ឌចំការមន ភ្នំពេញ

ប្រអប់សំបុត្រ : PO Box 499

ទូរស័ព្ទ : (៨៥៥) ២៣ ៣៦០ ៩៦៥/២១១ ៣៩១

ទូរសារ : (៨៥៥) ២៣ ៣៦០ ៩៦៥/២១៧ ៦២៦

អ៊ីមែល : licadho@camnet.com.kh



ខែកក្កដា ឆ្នាំ២០០២

# I- អារម្ភកថា

របាយការណ៍នេះពិពណ៌នាអំពីការងាររបស់ការិយាល័យពេទ្យលីកាដូក្នុងពន្ធនាគារកម្ពុជា ។ ទិន្នន័យនៃរបាយការណ៍ត្រូវបានប្រមូលដោយក្រុមពេទ្យ ហើយផ្អែកទៅលើការអង្កេត សម្ភាសន៍ និងទិន្នន័យអ្នកជំងឺ ។

ចំណុចសំខាន់មួយទៀតដែលត្រូវកត់សំគាល់នោះគឺ លីកាដូបានទទួលពត៌មានទាំងនេះពីការសម្ភាសន៍អ្នកទោសនៅក្នុងពន្ធនាគារ ។ វាមានការលំបាកណាស់ក្នុងការធ្វើសម្ភាសន៍អោយបានសម្ងាត់នោះ ដោយសារឆ្មាំពន្ធនាគារតែងតែមានវត្តមាននៅជិតកន្លែងសម្ភាសន៍ជានិច្ច ។ ឧបសគ្គក្នុងវិធីសាស្ត្រនៃការសម្ភាសន៍នេះ ត្រូវចាត់ទុកថា ជាកត្តាមួយដែលអាចប៉ះពាល់ទៅលើរបកគំហើញ ដោយវាហួសពីសមត្ថភាពរបស់បុគ្គលិកលីកាដូ ។

របាយការណ៍នេះមានគោលបំណងផ្តល់ដល់អ្នកអាននូវចំលើយទៅនឹងសំណួរដូចខាងក្រោម៖

- តើក្រុមគ្រូពេទ្យធ្វើការនៅឯណា ?
- តើក្រុមគ្រូពេទ្យព្យាបាលអ្នកណា ?
- តើពួកគ្រូពេទ្យទាំងនោះជួបប្រទះជំងឺអ្វីខ្លះ ?
- តើពួកគេកំពុងប្រឈមមុខនឹងបញ្ហាសុខភាពចម្បងអ្វីខ្លះ ?
- តើគេខិតខំធ្វើយ៉ាងណាដើម្បីការពារ ?

របាយការណ៍នេះមិនបានអះអាងថាជាការពិពណ៌នាទូលំទូលាយនៃបញ្ហាសុខភាពពន្ធនាគារដែលមាននៅកម្ពុជានោះទេ ។ អាស្រ័យដោយជួបការលំបាកក្នុងការប្រមូលពត៌មានរោគវិនិច្ឆ័យ និងទិន្នន័យនៃជំងឺមួយចំនួន ដូចជា HIV/AIDS ជាដើម ស្ទើរតែមិនបានរាយការណ៍នៅក្នុងស្ថិតិខាងក្រោម ។ ប៉ុន្តែ យើងជឿជាក់ថា ទោះបីជាមានការខ្វះខាតខ្លះក៏ដោយក៏របាយការណ៍នេះនៅតែជារបាយការណ៍ត្រឹមត្រូវសមហេតុផលមួយដែលឆ្លុះបញ្ចាំងនូវបញ្ហាសុខភាពចម្បងៗប្រឈមមុខនឹងប្រព័ន្ធពន្ធនាគារកម្ពុជាបច្ចុប្បន្ន ។

## II- បុព្វកថា

ដោយមានការអនុមតិ នូវ *បទបញ្ញត្តិជាបទដ្ឋានអប្បបរមាសំរាប់អនុវត្តចំពោះអ្នកទោស*[1] ដោយអង្គការសហប្រជាជាតិនៅឆ្នាំ ១៩៥៥ មក អង្គការពិភពលោកបានឈានជំហានដ៏សំខាន់មួយឆ្ពោះទៅរកភាពប្រាដកប្រជានូវសិទ្ធិជាមូលដ្ឋាននៃជនទាំងឡាយដែលត្រូវជាប់ឃុំឃាំងនៅទូទាំងពិភពលោក ។ សំខាន់ជាងនេះទៀតគឺ បញ្ញត្តិទាំងនេះបានផ្តោតការយកចិត្តទុកដាក់លើបញ្ហាសុខភាព និងការថែទាំសុខភាពមួយភាគធំ ។ ក្នុងការអនុវត្តន៏ដូច្នេះ គេបានទទួលស្គាល់ និងធ្វើអោយមានសុពលភាពនូវធម្មជាតិនៃសុខភាពទាំងឡាយ និង សិទ្ធិមនុស្សនៅក្នុងការគ្រប់គ្រងយុត្តិធម៌ ។

ក្នុងនាមជារដ្ឋសមាជិកមួយនៃអង្គការសហប្រជាជាតិ កម្ពុជាត្រូវមានកាតព្វកិច្ចប្រកាន់ខ្ជាប់នូវបទបញ្ញត្តិទាំងនេះ។ លើសពីនេះទៅទៀត *បទបញ្ញត្តិជាបទដ្ឋានអប្បបរមាសំរាប់អនុវត្តចំពោះអ្នកទោស* ក៏ជាផ្នែកមួយនៃច្បាប់កម្ពុជាផងដែរ។ មាត្រាទី ៨នៃក្រមព្រហ្មទណ្ឌដែលចូលជាធមិមាន[2] បានកំណត់ថា "ការប្រព្រិត្តិចំពោះអ្នកជាប់ពន្ធនាគារត្រូវតែអនុលោមទៅតាម *បទបញ្ញត្តិជាបទដ្ឋានអប្បបរមាសំរាប់អនុវត្តចំពោះអ្នកទោស* "

សិទ្ធិជាមូលដ្ឋាននៃអ្នកជាប់ពន្ធនាគារ ដែលស្ថិតក្រោមការឃុំឃាំងនៅកម្ពុជាត្រូវបានបញ្ជាក់សារឡើងវិញនៅឆ្នាំ ១៩៩៨ ព្រមទាំងមានច្បាប់កម្ពុជាមួយបន្ថែមទៀតគឺ ប្រកាសលេខ ២១៧ ដែលតាក់តែងដោយក្រសួងមហាផ្ទៃនៃរាជរដ្ឋាភិបាលកម្ពុជា ។ ឯកសារប្រកាសលេខ ២១៧ស្តីពីការគ្រប់គ្រងពន្ធនាគារនេះ[3] សំដៅដោះស្រាយបញ្ហាជាច្រើនដែលទាក់ទងទៅនឹងការគ្រប់គ្រងមណ្ឌលកែប្រែ ។ ក៏ដូចជា *បទបញ្ញត្តិជាបទដ្ឋានអប្បបរមាសំរាប់អនុវត្តចំពោះអ្នកទោស* ដែរ ប្រកាសលេខ ២១៧ បានសង្កត់ធ្ងន់ទៅលើសិទ្ធិមនុស្ស និង ការថែទាំសុខភាព ។

តាមរយៈសកម្មភាពរបស់ខ្លួន អង្គការលីកាដូបានចូលរួមចំណែកក្នុងទស្សនៈនេះ ព្រមទាំងខិតខំជំរឿននិងការពារសិទ្ធិពលរដ្ឋកម្ពុជាគ្រប់រូប រួមទាំងអ្នកដែលជាប់ឃុំឃាំងផងដែរ ។ ការិយាល័យពេទ្យរបស់លីកាដូបានដើរតួនាទីយ៉ាងសំខាន់ក្នុងកិច្ចការនេះ ។ តាមរយៈសកម្មភាពប្រចាំថ្ងៃអនុវត្តជាមួយអ្នកជាប់ពន្ធនាគារ និងបុគ្គលិកពន្ធនាគារ ក្រុមគ្រូពេទ្យបានខំប្រឹងប្រែងដើម្បីធានាអោយមានការគោរព និង ការអនុវត្តន៏បានតាមបទដ្ឋានអន្តរជាតិជាមូលដ្ឋាននៃសុខភាព និង លក្ខខណ្ឌនៃការរស់នៅ ។

---

[1] ឧបសម្ព័ន្ធ ខ: បទបញ្ញត្តិជាបទដ្ឋានអប្បបរាមាដើម្បីអនុវត្តចំពោះអ្នកជាប់ពន្ធនាគារ

[2] *ច្បាប់ព្រហ្មទណ្ឌអន្តរកាល ឆ្នាំ ១៩៩២*

[3] *ប្រកាសលេខ២១៧ របស់ក្រសួងមហាផ្ទៃស្តីពីការគ្រប់គ្រងពន្ធនាគារ ដែលចុះហត្ថលេខាដោយសហរដ្ឋមន្ត្រីក្រសួងមហា ផ្ទៃ ឯកឧត្តម យូ ហុកគ្រី និង ឯកឧត្តម ស ខេង នៅថ្ងៃទី ៣១ ខែមិនា ឆ្នាំ ១៩៩៨ ។*

បន្ទាប់ពីបានបង្កើតការិយាល័យពេទ្យនៅឆ្នាំ ១៩៩៣ លីកាដូបានចាប់ផ្តើមការងារវេជ្ជសាស្ត្រនៅពន្ធនាគារពីរនៅភ្នំពេញ គឺ ប៉េហ្ស៊ី និង តេ៣ ។ នៅពេលនោះ ពន្ធនាគារកម្ពុជាស្ថិតក្នុងសភាពមានវិបត្តិយ៉ាងធ្ងន់ធ្ងរ ហើយស្ថានភាពសុខភាពត្រូវជួបការលំបាកយ៉ាងខ្លាំង។ ជំងឺឆ្លងបានរាលដាលយ៉ាងសាហាវ ។ ជំងឺឆ្លងតាមផ្លូវដង្ហើមមានដូចជា របេង និង ជំងឺប៉ារ៉ាស៊ីតទាំងឡាយដូចជា រមាស់ មានការរាលដាលពេញពន្ធនាគារទាំងអស់ ។

ចាប់តាំងពី ៩ ឆ្នាំកន្លងមក ក្រុមពេទ្យនៃអង្គការលីកាដូបានបន្តការងាររបស់ខ្លួននៅតាមពន្ធនាគារកម្ពុជាជាច្រើន ។ បច្ចុប្បន្ននេះ ក្រុមពេទ្យមានគ្រូពេទ្យជំនាញផ្នែកសុខភាពដែលបំរើការពេញម៉ោងចំនួន ៥ នាក់និងទីប្រឹក្សាវេជ្ជសាស្ត្របរទេសម្នាក់ ។ ក្រុមពេទ្យនេះព្យាបាលអ្នកជាប់ពន្ធនាគារប្រមាណ១៧០០ នាក់ ដែលស្ថិតក្នុងពន្ធនាគារចំនួន ១២ កន្លែង ។ បុគ្គលិកពេទ្យទាំងនេះបានដើរតួនាទីយ៉ាងសំខាន់ដើម្បីធានាអោយមានសិទ្ធិមនុស្សជាមូលដ្ឋាន និង អោយមានការអនុវត្តន៍តាមតម្រូវការសុខភាពរបស់អ្នកជាប់ពន្ធនាគារទាំងឡាយតាមលទ្ធភាពគ្រប់ទីកន្លែង ។ លើសពីនេះទៅទៀត បុគ្គលិកពេទ្យរបស់លីកាដូបានជំរុញអោយមានការកែលំអនៅក្នុងប្រព័ន្ធពន្ធនាគារ ដោយធ្វើការសហការយ៉ាងជិតស្និទជាមួយមន្ត្រីនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ ព្រមទាំងបានចូលរួមជាសមាជិកសកម្មនៅក្នុងក្រុមផ្នែកសុខភាពពន្ធនាគាររបស់មេឌីខាំថែមទៀតផង ។

ក្រុមគ្រូពេទ្យលីកាដូបានប្រឹងប្រែងយ៉ាងខ្លាំងដើម្បីជួយព្យាបាលជំងឺអ្នកជាប់ពន្ធនាគារដោយការផ្តល់ថ្នាំសង្កូវ និងការថែទាំសុខភាពឥតគិតថ្លៃជាប្រចាំ ហើយក្រុមគ្រូពេទ្យនេះក៏បានយល់ច្បាស់ពីសារសំខាន់នៃការការពារផងដែរ ដោយបានអនុវត្តនូវវិធីសាស្ត្រថែទាំសុខភាពសាធារណៈ អនាម័យ និងកម្មវិធីម្ហូបអាហារផ្សេងៗនៅក្នុងពន្ធនាគារកម្ពុជាជាច្រើន។

នៅក្នុងកិច្ចខំប្រឹងប្រែងរបស់ខ្លួនដើម្បីការពារសិទ្ធិមនុស្សដល់ពលរដ្ឋកម្ពុជា លីកាដូនៅតែមានការខ្វាយខ្វល់យ៉ាងខ្លាំងអំពីស្ថានភាពលក្ខខណ្ឌសុខភាពនៅក្នុងពន្ធនាគារនៅកម្ពុជា ។ លីកាដូសូមអោយរាជរដ្ឋាភិបាលកម្ពុជា ក្រសួងសុខាភិបាល និងនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃផ្តោតការយកចិត្តទុកដាក់អោយបានខ្លាំងអស់ពីលទ្ធភាពដើម្បីសំរេចបាននូវកាតព្វកិច្ចរបស់ខ្លួនក្រោមច្បាប់កម្ពុជា និងដើម្បីអោយបានតាមកំរិតបទដ្ឋានអន្តរជាតិ ដែលបានកំណត់ឡើងសំរាប់លក្ខខណ្ឌពន្ធនាគារដូចមានចែងនៅក្នុង "*បទបញ្ញត្តិជាបទដ្ឋានអប្បបរមាសំរាប់អនុវត្តចំពោះអ្នកទោស*" ។

## III- សេចក្តីសង្ខេប

ចំនួនអ្នកជាប់ពន្ធនាគារនៅកម្ពុជា មានការកើនឡើងយ៉ាងលឿនក្នុងប៉ុន្មានឆ្នាំកន្លងទៅនេះ ។ នៅក្នុងពន្ធនាគារចំនួន ២០ កន្លែងដែលអង្គការលីកាដូបានធ្វើការស្រាវជ្រាវសង្កេតឃើញថា ចំនួនអ្នកជាប់ពន្ធនាគារមានការកើនឡើងរហូតដល់ ១២,៩ % កាលពីឆ្នាំកន្លងទៅ (ខែ ធ្នូ ២០០០-ធ្នូ ២០០១) ។ ពន្ធនាគារដដែលទាំងនេះ ចំនួនអ្នកជាប់ពន្ធនាគារបានកើនឡើងរហូតដល់ទៅ ៦៩% ក្នុងកំឡុងពេល ៣ ឆ្នាំ ពី (ខែ ធ្នូ

១៩៩៨-ធ្នូ២០០១) ។ រហូតមកដល់ខែធ្នូឆ្នាំ ២០០១ កន្លងទៅនេះ ពន្ធនាគារទាំងនេះមានអ្នកជាប់ពន្ធនាគារសរុបចំនួន ៥០៨៣ នាក់ ។

របាយការណ៍នេះ បានផ្តោតការយកចិត្តទុកដាក់ទៅលើការងារដែលបានអនុវត្តដោយបុគ្គលិកពេទ្យរបស់អង្គការលីកាដូ នៅក្នុងពន្ធនាគារកម្ពុជាចំនួន ១២កន្លែង ដែលត្រូវបានចូលទៅពិនិត្យព្យាបាលជាប្រចាំ ។ រហូតមកដល់ខែធ្នូ ឆ្នាំ ២០០១ កន្លងមកនេះ ពន្ធនាគារទាំងនេះរួមមានអ្នកជាប់ពន្ធនាគារសរុប ១.៧១៥ នាក់ ហើយដែលមួយចំនួនធំ (៥៧%) ជាប់នៅក្នុងពន្ធនាគារធំៗចំនួន ៣កន្លែង គឺៈ បាត់ដំបង កំពង់ចាម និងតាខ្មៅ។ នៅក្នុងឆ្នាំ ២០០១ នេះ បុគ្គលិកពេទ្យបានអនុវត្តការពិគ្រោះជំងឺដល់អ្នកជាប់ពន្ធនាគារសរុប ៤៩២៤ នាក់ ហើយបានរកឃើញរោគវិនិច្ឆ័យចំនួន ៥២៤៥ ករណី ។ នៅក្នុងកំឡុងពេលនេះដែរ ៧,៧ %នៃអ្នកដែលបានទទួលការពិនិត្យព្យាបាលនោះ ជាស្ត្រីភេទ ហើយអ្នកជាប់ពន្ធនាគារជាស្ត្រីភេទ មានចំនួនរហូតដល់ទៅ ៦% នៃអ្នកជាប់ពន្ធនាគារទាំងអស់នៅក្នុងពន្ធនាគារទាំងនេះ ។

ជំងឺភាគច្រើនដែលគ្រូពេទ្យអង្គការលីកាដូបានពិនិត្យព្យាបាលនោះ ជាជំងឺដែលអាចការពារបាន ។ នៅក្នុងឆ្នាំ ២០០១ កន្លងទៅនេះ មានរោគវិនិច្ឆ័យប្រហែល ២០% នៃរោគវិនិច្ឆ័យដែលបានជួបប្រទះ គឺជាប្រភេទដែលជាប់ពាក់ព័ន្ធទៅនឹងលក្ខខណ្ឌកង្វះអនាម័យជាទូទៅនៅក្នុងពន្ធនាគារកម្ពុជាបច្ចុប្បន្ន ។ លក្ខខណ្ឌនេះ គឺជាលទ្ធផលដែលមិនអាចជៀសវាងបាន ដែលបណ្តាលមកពីកំណើនអ្នកជាប់ពន្ធនាគារដែលបានកើតឡើងនៅក្នុងពន្ធនាគារក្នុងប៉ុន្មានឆ្នាំកន្លងទៅនេះ ។ បន្ទប់ឃុំឃាំងនៅក្នុងពន្ធនាគារមួយទំហំតូចចង្អៀតមានការយ៉ាប់យ៉ឺនខ្លាំងណាស់ដែលជាការគំរាមកំហែងដោយផ្ទាល់ទៅលើសុខភាពអ្នកជាប់ពន្ធនាគារ ។ ការសិក្សាថ្មីៗនៅក្នុងពន្ធនាគារភ្នំពេញមួយបានបង្ហាញអោយឃើញថា ទំហំផ្ទៃបន្ទប់ឃុំឃាំងជាមធ្យមសំរាប់អ្នកជាប់ពន្ធនាគារម្នាក់គឺត្រឹមតែ ១,៣ មែត្រការ៉េប៉ុណ្ណោះ ហើយមានអ្នកជាប់ពន្ធនាគារចំនួន ១៤% ស្ថិតនៅក្នុងទំហំផ្ទៃបន្ទប់ឃុំឃាំងតូចជាង ១ មែត្រការ៉េទៅទៀត ។

នៅក្នុងបន្ទប់ឃុំឃាំងដ៏ចង្អៀតបែបនេះជំងឺឆ្លងអាចរាលដាលយ៉ាងលឿន។ ការពិត នៅក្នុងឆ្នាំ ២០០១ កន្លងទៅនេះជំងឺឆ្លងមានប្រហែលជា៤៧,៧% ក្នុងចំណោមរោគវិនិច្ឆ័យទាំងឡាយដែលបានរកឃើញនៅក្នុងពន្ធនាគារដោយគ្រូពេទ្យលីកាដូ ។ ជំងឺរមាស់គឺជាប្រភេទជំងឺប៉ារ៉ាស៊ីតលើស្បែក ដែលបានកើតឡើងច្រើនបំផុត ។ ជំងឺនេះងាយឆ្លងបំផុតហើយបានបណ្តាលអោយមានការរំខានយ៉ាងខ្លាំងដល់អ្នកជាប់ពន្ធនាគារដែលកើតជំងឺនេះ ។ ថ្មីៗនេះអង្គការលីកាដូបានអនុវត្តនូវកម្មវិធីការពារ និង ព្យាបាលជំងឺរមាស់ នៅពន្ធនាគារតាខ្មៅ និង ប៉ៃហ្សិ ហើយលទ្ធផលបានបង្ហាញអោយឃើញថា ៥០,៣%នៃអ្នកជាប់ពន្ធនាគារទាំងអស់នៅតាខ្មៅបានកើតរមាស់ និង ៣១,២% នៃអ្នកជាប់ពន្ធនាគារទាំងអស់ នៅប៉ៃហ្សិក៏បានកើតរមាស់ដែរ ។

ប្រភពសំខាន់មួយទៀតនៃជំងឺដែលអាចទប់ស្កាត់បាននៅក្នុងពន្ធនាគារ គឺការផ្តល់អាហារមិនគ្រប់គ្រាន់ជាទូទៅដល់អ្នកជាប់ពន្ធនាគារទាំងឡាយ ។ យោងតាមបញ្ញត្តិរបស់នាយកដ្ឋានពន្ធនាគារ ពន្ធនាគារនីមួយៗត្រូវ

ផ្តល់របប ១.០០០ រៀលម្នាក់ក្នុង១ថ្ងៃ ដល់អ្នកជាប់ពន្ធនាគារសំរាប់ម្ហូបអាហារ ។ តែផ្ទុយទៅវិញ ថវិកានេះត្រូវបានបុគ្គលិកពន្ធនាគារដកយកមួយផ្នែកទៅចំណាយលើកិច្ចការផ្សេងៗដែលពាក់ព័ន្ធទៅនឹងជីវភាពប្រចាំថ្ងៃរបស់ពន្ធនាគារថែមទៀត ។ ហើយជាលទ្ធផល អ្នកជាប់ពន្ធនាគារទាំងនោះពុំបានទទួលរបបអាហារគ្រប់គ្រាន់ដើម្បីអោយមានសុខភាពល្អទេ ។ នៅក្នុងឆ្នាំ ២០០១ កន្លងទៅនេះ មានរោគវិនិច្ឆ័យប្រមាណជា ១៣.៣% ក្នុងចំណោមរោគវិនិច្ឆ័យទាំងឡាយដែលប្រទះឃើញនៅក្នុងឆ្នាំនោះ គឺជាប្រភេទរោគដែលបណ្តាលមកពីកង្វះជីវជាតិ និងកង្វះម្ហូបអាហារ។ បើពិនិត្យទៅលើច្បាប់កម្ពុជាបច្ចុប្បន្ន បានចែងយ៉ាងច្បាស់នៅក្នុងប្រកាសលេខ ២១៧ (១៩៩៨) និងចែងនៅក្នុងមាត្រា ៨ នៃក្រមព្រហ្មទណ្ឌអន្តរកាល (១៩៩២) ដែលបានលើកឡើងដោយច្បាប់ថា *ត្រូវផ្តល់ម្ហូបអាហារសំរាប់បរិភោគអោយបានគ្រប់គ្រាន់ដល់អ្នកជាប់ពន្ធនាគារទាំងឡាយ* ។

បរិមាណនិងគុណភាពទឹកសំរាប់បរិភោគនៅក្នុងពន្ធនាគារកម្ពុជា ក៏ជាបញ្ហាមួយត្រូវខ្វាយខ្វល់ផងដែរ។ នៅក្នុងឆ្នាំ ២០០១ កន្លងទៅនេះ អង្គការលីកាដូបានចាប់ផ្តើមធ្វើការពិសោធន៍គុណភាពទឹក ដែលជាផ្នែកមួយនៃកម្មវិធីអនាម័យនិងការការពារជំងឺរមាស់ ដែលត្រូវបានអនុវត្តនៅពន្ធនាគារប៉ៃហ្សី និង តាខ្មៅ ។ លទ្ធផលបឋមបានបង្ហាញអោយឃើញថា ទឹកនៅប៉ៃហ្សីអាចផឹកបាន ប៉ុន្តែទឹកដែលប្រើសំរាប់ផឹកនៅពន្ធនាគារតាខ្មៅគឺមិនអាចផឹកបានអាស្រ័យដោយមានភាពកខ្វក់ដែលបណ្តាលមកពីពពួកបាក់តេរី និងសារធាតុគីមី ។ នៅក្នុងច្បាប់កម្ពុជាបច្ចុប្បន្នក៏បានចែងច្បាស់នៅក្នុងប្រកាសលេខ ២១៧ (១៩៩៨) និង មាត្រា ៨ នៃក្រមព្រហ្មទណ្ឌអន្តរកាល(១៩៩២) ផងដែរថា តាមច្បាប់ *ត្រូវផ្តល់ទឹកស្អាតដល់អ្នកជាប់ពន្ធនាគារ* ។

អង្គការលីកាដូក៏បានដឹងដែរថា អ្នកជាប់ពន្ធនាគារជាស្ត្រីភេទមានតំរូវការសុខភាពពិសេសរបស់ពួកគេដោយឡែក ។ នៅក្នុងឆ្នាំ ២០០១ កន្លងទៅនេះ ជំងឺរលាកទ្វារមាស និងរលាកបង្ហូរនោមមានរហូតដល់ទៅ ៥% និង ១,៧%ក្នុងមួយមុខៗនៃរោគវិនិច្ឆ័យទាំងឡាយដែលបានជួបប្រទះក្នុងចំណោមស្ត្រី ។ លើសពីនេះទៀតក្នុងឆ្នាំ២០០១ អ្នកជាប់ពន្ធនាគារជាស្ត្រីដែលមានផ្ទៃពោះចំនួន៧នាក់ត្រូវបានផ្គត់ផ្គង់ ថែទាំ ព្យាបាលដោយក្រុមពេទ្យ ។ ការរំលោភផ្លូវភេទចំពោះស្ត្រីដែលជាប់ពន្ធនាគារនៅតែជាការព្រួយបារម្ភមួយ យ៉ាងខ្លាំងផងដែរចំពោះសុខភាព ។

នៅក្នុងឆ្នាំ២០០១ អង្គការលីកាដូបានបន្តគោលនយោបាយរបស់ខ្លួនក្នុងការពង្រីកសេវាកម្មថែទាំសុខភាពចំពោះអ្នកយាមពន្ធនាគារ ហើយបានពិនិត្យព្យាបាលបានចំនួន ១៣០៦ នាក់ ។

ជាការសន្និដ្ឋាន ជម្ងឺភាគច្រើនដែលមានក្នុងពន្ធនាគារកម្ពុជាមានការងាយស្រួលក្នុងការការពារ ព្រោះប្រមាណ ១៣.៣% នៃរោគវិនិច្ឆ័យដែលបានរកឃើញក្នុងឆ្នាំ២០០១ គឺកង្វះវិតាមីន និងម្ហូបអាហារផ្ទាល់ ហើយ ២០% ទៀតទាក់ទិននិងលក្ខណៈកង្វះអនាម័យ និងការឃុំខ្លួនច្រើនហួសប្រមាណនៅក្នុងបន្ទប់ពន្ធនាគារ ។ វាជាការសមស្រប ដូច្នេះថា ប្រភេទជម្ងឺមួយចំនួននៅក្នុងពន្ធនាគារអាចត្រូវបានកាត់បន្ថយមួយភាគបី (៣៣.៣%)

តាមរយៈការខិតខំបង្កើនផ្នែកអនាម័យ បន្ថយការឃុំខ្លួនច្រើនហួសហេតុ និងផ្តល់នូវម្ហូបអាហារគ្រប់គ្រាន់សមស្របទៅតាមច្បាប់កម្ពុជា ។

## IV- ចំនួនអ្នកជំងឺ

រហូតមកដល់ខែធ្នូ ឆ្នាំ ២០០១ កន្លងទៅនេះចំនួនអ្នកជាប់ពន្ធនាគារមានរហូតដល់ទៅ៥. ០៨៣ នាក់[4] នៅក្នុងពន្ធនាគារចំនួន២០ ដែលអង្គការលីកាដូ[5] ធ្វើការជាមួយ ។ ក្នុងកំឡុងឆ្នាំ ២០០១ បុគ្គលិកពេទ្យរបស់អង្គការលីកាដូបានចុះទៅពិនិត្យព្យាបាលជារៀងរាល់ខែក្នុងពន្ធនាគារចំនួន១១ កន្លែង ក្នុងចំណោមពន្ធនាគារទាំងអស់ ហើយលើសពីនេះទៅទៀតនៅត្រីមាសទីបីនៃឆ្នាំ ២០០១ នេះ បុគ្គលិកពេទ្យយើងក៏បានដំណើរការចុះទៅពិនិត្យព្យាបាលជាប្រចាំរៀងរាល់ខែនៅពន្ធនាគារទី ១២ ដែលស្ថិតនៅក្នុងភូមិសាស្រ្តខេត្តកំពង់ចាមថែមទៀត ។ ដូច្នេះគ្រូពេទ្យលីកាដូបច្ចុប្បន្នបាននឹងកំពុងធ្វើការពិនិត្យព្យាបាលនៅក្នុងមណ្ឌលកែប្រែចំនួន ១២ ដូចខាងក្រោម ។

១- ពន្ធនាគារខេត្តបាត់ដំបង

២- ពន្ធនាគារខេត្តកំពង់ចាម

៣- ពន្ធនាគារ ខេត្តកណ្តាល (តាខ្មៅ)

៤- ពន្ធនាគារ ក្រុងព្រះសីហនុ

៥- ពន្ធនាគារខេត្តតាកែវ

៦- ពន្ធនាគារខេត្តព្រៃវែង

៧- ពន្ធនាគារខេត្តកំពង់ធំ

៨- ពន្ធនាគារខេត្ត ស្វាយរៀង

៩- ពន្ធនាគារខេត្តកោះកុង

១០- ពន្ធនាគារប៉េស៊ី

១១- ពន្ធនាគារខេត្តពោធិសាត់ និង

១២- ពន្ធនាគារទួលស្លែង

---

[4] *ជាឆ្នាំមួយដែលមានកំណើន ១២,៩ %*

[5] *ការិយាល័យស៊ើបអង្កេតសិទ្ធិមនុស្សលីកាដូ ពិនិត្យមើលជាប្រចាំទៅលើពន្ធនាគារចំនួន ១២ ដែលបានរៀបរាប់ខាងលើ ហើយលើសពីនេះមានពន្ធនាគារមួយចំនួនទៀត ដូចជា សៀមរាប -កំពង់ស្ពឺ-កំពង់ឆ្នាំង-បន្ទាយមានជ័យ- ម១ -ម២ និង ម៣ ។*

នៅក្នុងពន្ធនាគារទាំង ១២ នេះ រួមមានអ្នកជាប់ពន្ធនាគារសរុប ១៧១៥ នាក់[6] ។ ចំនួនអ្នកជាប់ពន្ធនាគារតែងតែមានការប្រែប្រួលខុសគ្នានៅក្នុងចំណោមពន្ធនាគារទាំងឡាយ ។ ចំនួនអ្នកជាប់ពន្ធនាគារទាបបំផុតគឺ១៥ នាក់ ហើយខ្ពស់បំផុតអាចមានទៅដល់ ៤០០នាក់ ។ ភាគច្រើននៃអ្នកជាប់ ពន្ធនាគារទាំងនោះ (៥៧%) គឺពន្ធនាគារខេត្តបាត់ដំបង ខេត្តកំពង់ចាម និង ពន្ធនាគារតាខ្មៅ ខេត្តកណ្ដាល ។

***រូបទី ១ : ចំនួនអ្នកជាប់ពន្ធនាគារ (ខែ ធ្នូ ឆ្នាំ ២០០១)***




នៅឆ្នាំ ២០០១ កន្លងទៅនេះ បុគ្គលិកពេទ្យបានធ្វើការពិនិត្យពិគ្រោះជំងឺ[7] ដល់អ្នកជាប់ពន្ធនាគារសរុប ៤.៩២៤ ដង នៅក្នុងពន្ធនាគារទាំង ១២ កន្លែងនេះ ។ បុគ្គលិកពេទ្យទាំងនោះក៏បានពិនិត្យពិគ្រោះជំងឺបន្ថែមទៀតនៅពន្ធនាគារដទៃៗទៀតក្នុងករណីចាំបាច់ ។

***រូបទី ២: ការពិគ្រោះជំងឺអ្នកជាប់ពន្ធនាគារតាមត្រីមាសក្នុងឆ្នាំ ២០០១***

---

[6] *ឆ្នាំមួយដែលមានកំណើន ៣. ៦%*

[7] *មានន័យថា ការពិនិត្យពិគ្រោះជំងឺអ្នកជាប់ពន្ធនាគារមួយនាក់ គឺកំណត់យកចំនួនការពិនិត្យនោះតែម្ដងគត់រវាងគ្រូពេទ្យម្នាក់ និង អ្នកជាប់ពន្ធនាគារម្នាក់ ។ ចំនួនពិគ្រោះជំងឺមិនស្មើនឹងចំនួនអ្នកជំងឺទេ ។ ឧទាហរណ៍ : បើយើងបានពិនិត្យអ្នកជាប់ពន្ធនាគារម្នាក់ ៣ ដងដោយឡែកពីគ្នា - នោះរាប់ថា ចំនួនពិគ្រោះជំងឺ ៣ ដង ។*




ក្នុងចំណោមអ្នកជាប់ពន្ធនាគារដែលបានទទួលការពិនិត្យព្យាបាលជំងឺក្នុងឆ្នាំ២០០១កន្លងមកនេះ ចំនួនប្រហែលជា ៧,៧% ជាស្ត្រីភេទ (មើលរូបទី ៣) ។ ចំនួនអ្នកជាប់ពន្ធនាគារជាស្ត្រីនៅក្នុងពន្ធនាគារទាំង១២ នេះមានប្រមាណ ៦% នៃចំនួនអ្នកជាប់ពន្ធនាគារទាំងអស់ ។ ចំនួនទាំងនេះបានបង្ហាញអោយឃើញថា អ្នកជាប់ពន្ធនាគារជាស្ត្រីភេទកំពុងទទួលនូវលទ្ធភាពពិនិត្យព្យាបាលសមស្របទៅនឹងសេវាថែទាំសុខភាពរបស់យើង ។

***រូបទី ៣ : ការបង្ហាញចំនួនអ្នកជាប់ពន្ធដែលបានទទួលការពិនិត្យព្យាបាលតាមភេទឆ្នាំ ២០០១***




## V- លទ្ធភាពក្នុងការថែទាំសុខភាព

*“អ្នកជាប់ពន្ធនាគារទាំងឡាយត្រូវតែមានលទ្ធភាពក្នុងការទទួលសេវាសុខភាពដែលមាននៅក្នុងប្រទេសដោយពុំមានការរើសអើងដែលពាក់ព័ន្ធទៅនឹងស្ថានភាពច្បាប់ឡើយ ”*

**- បទបញ្ញត្តិជាបទដ្ឋានអប្បបរមាសំរាប់អនុវត្តចំពោះអ្នកទោស**

*"ពន្ធនាគារនីមួយៗ ត្រូវមានអ្នកថែទាំសុខភាព ដែលមានភារកិច្ចទទួលខុសត្រូវដូចខាងក្រោម :*

*- ថែទាំសុខភាពអ្នកជាប់ពន្ធនាគារ*

*- ផ្តល់ជំនួយសង្គ្រោះបន្ទាន់ផ្នែកពេទ្យ*

*- ពិនិត្យសុខភាពអ្នកជាប់ពន្ធនាគារតាមតម្រូវការ ។*

**-ប្រកាសលេខ ២១៧ស្តីការគ្រប់គ្រងពន្ធនាគារ (១៩៩៨)**

*"ប្រធានពន្ធនាគារនឹងត្រូវចេញលិខិតអនុញ្ញាតមួយអោយបានត្រឹមត្រូវ នៅពេលដែលអ្នកថែទាំសុខភាពពិនិត្យជម្ងឺរួចហើយ ហើយយល់ឃើញថា អ្នកជាប់ពន្ធនាគារនោះឈឺ ឬមានរបួសដែលតម្រូវអោយមានការពិនិត្យឬព្យាបាលនៅខាងក្រៅ ដូចជា នៅមន្ទីរពេទ្យជាដើម"*

**-ប្រកាសលេខ ២១៧ ស្តីពីការគ្រប់គ្រងពន្ធនាគារ (១៩៩៨)**

ក្រៅពីពន្ធនាគារទាំង ១២ កន្លែងដែលគ្រូពេទ្យលីកាដូបានធ្វើការពិនិត្យព្យាបាលជាប្រចាំ សុទ្ធតែមានបុគ្គលិកពេទ្យយ៉ាងហោចណាស់ក៏ម្នាក់ដែរ ដែលចាត់តាំងដោយក្រសួងមហាផ្ទៃ ក្នុងចំណោមបុគ្គលិកពន្ធនាគារ ។ ជាអកុសល នៅកម្ពុជាករណីជាធម្មតាគឺ បុគ្គលិកថែទាំសុខភាពទាំងនោះមានបទពិសោធន៍ទាប ហ្វឹកហ្វឺនបានតិចតួច ព្រមទាំងខ្វះសម្ភារៈបរិក្ខារពេទ្យជាមូលដ្ឋាន ។ ជាធម្មតា បុគ្គលិកពេទ្យទាំងនោះបានទទួលការហ្វឹកហ្វឺនត្រឹមតែជាគិលានុបដ្ឋាកបឋមប៉ុណ្ណោះ ។ អង្គការលីកាដូក៏បានដឹងថា យ៉ាងហោចណាស់ក៏មានបុគ្គលិកពេទ្យពន្ធនាគារម្នាក់ដែរ ដែលមិនបានទទួលការហ្វឹកហ្វឺនផ្នែកវេជ្ជសាស្ត្រជាផ្លូវការទាល់តែសោះ ។

ចំពោះប្រាក់ខែ បុគ្គលិកពេទ្យទាំងនោះទទួលបានប្រហែលជា ៧០.០០០ រៀល (១៧,៥០ដុល្លា)ក្នុង១ខែ។ ជាលទ្ធផល បុគ្គលិកពេទ្យពន្ធនាគារមួយចំនួនមិនសូវបានទៅធ្វើការនៅពន្ធនាគារទេ ដោយត្រូវចំណាយពេលរបស់គេធ្វើកិច្ចការដទៃ ដើម្បីរកចំណូលបន្ថែមនៅកន្លែងផ្សេងវិញ។

អាស្រ័យដោយប្រភពហិរញ្ញវត្ថុ និងបរិក្ខារពេទ្យមានកំរិត គ្រូពេទ្យពន្ធនាគារច្រើនតែសុំថវិកាពីអ្នកជាប់ពន្ធនាគារដែលឈឺ ឬពីគ្រួសាររបស់ពួកគេក្នុងការចាត់ចែងព្យាបាលជំងឺ ។ ថវិកានេះនឹងត្រូវយកទៅចំណាយលើការព្យាបាល ឬ លើការដឹកជញ្ជូនទៅមន្ទីរពេទ្យដែលនៅជិតនោះ ។ ក្នុងកាលៈទេសៈខ្លះ ការសុំថវិកានោះបុគ្គលិកពេទ្យពន្ធនាគារអាចមានចេតនាដើម្បីលៃយកចំណេញខ្លះក៏មាន ។

ជាញឹកញាប់ណាស់ - ប្រសិនបើអ្នកជាប់ពន្ធនាគារណាម្នាក់ឈឺ ហើយខ្វះថវិកាចាំបាច់ដើម្បីទិញថ្នាំ ឬធ្វើសោហ៊ុយទៅមន្ទីរពេទ្យនោះ គេច្រើនតែមិនបានយកចិត្តទុកដាក់ពីតំរូវការព្យាបាលរបស់អ្នកនោះទេ ហើយទុកចោលរហូតទាល់តែឈឺធ្ងន់ធ្ងរហួសពេល ។ វាពុំមែនមិនធម្មតាទេចំពោះនាយកពន្ធនាគារម្នាក់ត្រូវតែរៀបចំបញ្ជូនអ្នកជាប់ពន្ធនាគារដែលឈឺជិតស្លាប់ទៅហើយនោះទៅមន្ទីរពេទ្យដើម្បីចៀសផុតពីការទទួលខុសត្រូវ ។

ករណីសិក្សាខាងក្រោម ផ្អែកទៅលើការបង្ហាញរបស់ជនរងគ្រោះ ដែលរៀបរាប់អំពីឧបសគ្គមួយចំនួនដែលរារាំងមិនអាចអោយគាត់ទទួលការថែទាំសុខភាពបាននៅក្នុងពន្ធនាគារ ។

**ករណីសិក្សាទី ១**

រិទ្ធ ជាបុរសដែលមានអាយុត្រឹមតែ ១៦ឆ្នាំ ត្រូវបានចាប់ខ្លួននៅឆ្នាំ ២០០១ ក្នុងខណៈដែលប៉ុនប៉ងលួចខ្សែករបស់ស្ត្រីម្នាក់នៅភ្នំពេញ ។ គាត់និងមិត្តភ័ក្តិម្នាក់បានព្យាយាមឆក់ខ្សែក នៅពេលដែលកំពុងជិះម៉ូតូដែងយ៉ាងលឿននោះ ។ គំរោងការប្លន់នោះបានបរាជ័យនៅពេលដែលម៉ូតូរបស់ រិទ្ធ ត្រូវបានបុកដួលក្នុងពេលព្យាយាមលួចឆក់នោះ ។ រិទ្ធ បានព្យាយាមរត់គេចពីទីនោះដោយថ្មើជើង ប៉ុន្តែគាត់ក៏ត្រូវកងនគរបាលនៅជិតនោះចាប់បានភ្លាម១ ។ ភ្លាមនោះ ហ្វូងមនុស្សជាច្រើនបានចោមវាយ រិទ្ធ ដោយដំបង និងដុំថ្ម ។ គាត់បានប្រាប់ថា គាត់បានសន្លប់តតដឹងខ្លួនភ្លាម នៅពេលដែលគេចោលដុំថ្មត្រូវចំក្បាល ។

នៅពេល រិទ្ធ ដឹងខ្លួនឡើងវិញ គាត់បានទៅដល់ប៉ុស្តិ៍នគរបាលនៅមូលដ្ឋាននោះទៅហើយ ។ ខណៈដែលជាប់ឃុំនៅក្នុងប៉ុស្តិ៍នគរបាលនោះ មន្ត្រីនគរបាលម្នាក់បានវាយគាត់ ២-៣ ដងពីក្រោយខ្នង និងក្បាលដោយស្វ័យកាំភ្លើងអាកា ៤៧ ។ ពេលនោះ រិទ្ធក៏សន្លប់ម្តងទៀត ។

នៅពេល រិទ្ធ ដឹងខ្លួនវិញម្តងទៀត ពេលនោះជាពេលល្ងាច ហើយមាននគរបាលជាច្រើននៅជុំវិញប៉ុស្តិ៍នគរបាលនោះ ។ តាមសំដី រិទ្ធ និយាយថាៈ មាននគរបាលម្នាក់បានអះអាងថា គាត់ត្រូវជាបងប្អូនជនរងគ្រោះដែល រិទ្ធ ប្លន់នោះ ។ មន្ត្រីនគរបាលបានបន្តវាយគាត់ទៀត ពេលនេះគេបានទាត់នឹងស្បែកជើងប៊ូតចំក្បាល និងខ្លួន ។

ពេលព្រឹកព្រលឹមថ្ងៃស្អែកឡើង រិទ្ធ មានការឈឺចាប់យ៉ាងខ្លាំងពេញទាំងខ្លួន ។ ហើយនៅព្រឹកនោះនគរបាលបានយកគាត់ទៅមន្ទីរពេទ្យព្រះមុនីវង្ស ប៉ុន្តែប្រហែល២ម៉ោងក្រោយមក រិទ្ធ បានត្រឡប់មកដល់ប៉ុស្តិ៍នគរបាលវិញ ។ ថ្ងៃបន្ទាប់មកទៀត រិទ្ធ ក៏បានរងការឈឺចុកចាប់ពាសពេញរាងកាយម្តងទៀត ។ គេបាននាំគាត់ទៅមន្ទីរពេទ្យព្រះមុនីវង្សម្តងទៀត ហើយពេលនោះគាត់មានការអស់កំលាំងយ៉ាងខ្លាំងភ្លាម១ ។

ក្រោយពីនោះមកបន្តិច គេបាននាំ រិទ្ធ ទៅពន្ធនាគារមួយក្នុងភ្នំពេញ ។ ខណៈទៅដល់ពន្ធនាគារនោះ រិទ្ធ បានទទួលរងការឈឺចាប់ពាសពេញខ្លួនម្តងទៀត ហើយថែមទាំងសន្លប់តតដឹងខ្លួនទៀតផង ។ ការឈឺចុកចាប់នោះជាធម្មតាមានរយៈពេលប្រមាណ២០នាទី ។ ពេលគាត់នៅក្នុងពន្ធនាគារ រិទ្ធ មិនដែលបានទទួលថ្នាំសំរាប់ការឈឺចាប់នោះទេ ហើយជាធម្មតាគេទុកគាត់ចោលនៅលើគ្រែមួយតែម្នាក់ឯងក្នុងពេលដែលគាត់ដេកថ្ងូរនោះ ។

អង្គការលីកាដូបានដឹងអំពីករណីរបស់ រិទ្ធ នេះនៅថ្ងៃទី៣ ដែលគាត់នៅក្នុងពន្ធនាគារ ហើយអាចធ្វើអន្តរាគមន៍ទាន់ពេលដោយបញ្ចុះបញ្ចូលបុគ្គលិកពន្ធនាគារអោយនាំគាត់ទៅមន្ទីរពេទ្យ ។ ពេលសួរថា ហេតុអ្វីបានជាមិនបានយកគាត់ទៅមន្ទីរពេទ្យ ? បុគ្គលិកពន្ធនាគារនោះបានបញ្ជាក់ពីការខ្វះខាតថវិកាសំរាប់ដឹកជញ្ជូន និងសំរាប់ព្យាបាល រិទ្ធ ។

### អនុសាសន៍

- រាជរដ្ឋាភិបាលកម្ពុជាត្រូវតែធានាអោយមានការថែទាំសុខភាពគ្រប់គ្រាន់ និងសមរម្យសំរាប់អ្នកជាប់ពន្ធនាគារគ្រប់រូបដែលជាប់ឃុំឃាំងក្នុងពន្ធនាគារកម្ពុជា ស្របទៅតាមច្បាប់របស់កម្ពុជា ។

## VI- រោគវិនិច្ឆ័យ ចំនួន ២០ ប្រភេទដែលច្រើនបំផុតក្នុងឆ្នាំ ២០០១

តារាងខាងក្រោមបង្ហាញនូវរោគវិនិច្ឆ័យចំនួន២០ប្រភេទដែលបានព្យាបាលច្រើនបំផុតក្នុងចំណោមអ្នកជាប់ពន្ធនាគារនៅក្នុងឆ្នាំ ២០០១ កន្លងទៅនេះ ។ នេះគឺជារោគវិនិច្ឆយដែលមានបរិមាណខ្ពស់រហូតដល់ទៅ ៧៨,៧% ក្នុងចំណោមរោគវិនិច្ឆ័យផ្សេងៗទៀតដែលបានជួបប្រទះក្នុងកំឡុងពេលនោះ ។

*តារាងទី ៤: រោគវិនិច្ឆ័យចំនួន ២០ ដែលកើតមានច្រើនបំផុតក្នុងចំណោមអ្នកជាប់ពន្ធនាគារ*

| រោគវិនិច្ឆ័យ | ចំនួនរោគវិនិច្ឆ័យ | ភាគរយ |
|---|---|---|
| ផ្តាសសាយធំ | ៧៤២ | ១៤,១ |
| ស្អូក | ៤២៣ | ៨,១ |
| ឈឺក្បាល | ៣១៧ | ៦,០ |
| មិនរំលាយអាហារ | ៣០៤ | ៥,៨ |
| រលាកក្រពះ | ២៨៩ | ៥,៥ |
| ជំងឺខ្វះជីវជាតិ( ទូទៅ) | ២៦៧ | ៥,១ |
| ជំងឺលើសឈាម | ១៧៣ | ៣,៣ |
| រមាស់ | ១៦១ | ៣,១ |
| រាគ | ១៥៩ | ៣,០ |
| ឈឺឆ្អឹងឆ្អែង | ១៥០ | ២,៩ |
| ស្រែង | ១៤៩ | ២,៨ |
| ឈឺសាច់ដុំ | ១៥០ | ២,៩ |
| រលាកសរសៃប្រសាទ | ១៣៨ | ២,៦ |
| ដំបៅក្លាយ | ១៣០ | ២,៥ |
| វិលមុខធឹងធោង | ១០៨ | ២,១ |
| រលាកបំពង់នោម | ៩៩ | ១,៩ |
| គ្រុនពោះវៀន | ៩៨ | ១,៩ |

| | | |
|---|---|---|
| រលាកសួត | ៩៦ | ១,៨ |
| បូស | ៩០ | ១,៧ |
| ឈឺសន្លាក់ដៃជើង | ៩០ | ១,៧ |
| **សរុប** | **៤១២៨** | **៧៨,៧** |

## VII- កំណត់សំគាល់ចំពោះស្ថិតិ

ចំពោះគោលបំណងនៃស្ថិតិនេះ លីកាដូមិនបានធ្វើការបែងចែកអោយដាច់រវាងរោគសញ្ញា និងរោគវិនិច្ឆ័យទេ ។ អាស្រ័យដោយលទ្ធភាពមានកំរិតនៅក្នុងការផ្តល់សេវាសុខភាពនៅពន្ធនាគារកម្ពុជា គ្រូពេទ្យជួនកាលមិនអាចធ្វើរោគវិនិច្ឆ័យអោយបានត្រឹមត្រូវ ដូច្នេះហើយជាលទ្ធផលយើងធ្វើចំណាត់ថ្នាក់ជំងឺមួយចំនួនទៅតាមរោគសញ្ញាតែម្តង ។ ក្នុងការអនុវត្តន៍បែបនេះ យើងបានបញ្ចូលចំនួនរោគសញ្ញាទៅក្នុងស្ថិតិនៃរោគវិនិច្ឆ័យដែរ ។

ដូចដែលបានលើកឡើងត្រួសៗនៅក្នុងបុព្វកថា មានជំងឺមួយចំនួន ដូចជា HIV/AIDS គឺស្ទើរតែមិនបានរាយការណ៍នៅក្នុងស្ថិតិនេះទេ ។ ករណីនេះគឺបណ្តាលមកពីការមិនបានអនុវត្តជារឿយៗក្នុងការពិនិត្យឈាម ឬ មិនចង់អោយមានការពិនិត្យឈាមក៏មាន ។ លើសពីនេះទៅទៀត ការិយាល័យពេទ្យលីកាដូយើងបានត្រឹមតែបញ្ចូលរោគវិនិច្ឆ័យបឋមទៅក្នុងស្ថិតិប៉ុណ្ណោះ នៅក្នុងការអនុវត្តន៏ការងារភាគច្រើនរបស់ខ្លួនក្នុងឆ្នាំ២០០១កន្លងទៅនេះ ។ ហើយជាលទ្ធផលប្រភេទជំងឺទាំងនេះ ឬជាមូលហេតុដើមនៃជំងឺនោះច្រើនតែមិនបានបញ្ចូលទៅក្នុងស្ថិតិ ។ បច្ចុប្បន្ននេះយើងកំពុងតែដំណើរការកែលំអវិធីសាស្ត្រធ្វើស្ថិតិរបស់យើងអោយបានប្រសើរជាងមុនដើម្បីកែតំរូវបញ្ហាដែលនៅសេសសល់ទាំងនេះ ។ អាស្រ័យដោយបញ្ហាទាំងនេះនៅជិតជាប់ក្នុងគំនិតស្ថិតិរបស់ការិយាល័យពេទ្យនេះអាចយកទៅប្រើជាឯកសារដ៏មានប្រយោជន៏ជាទីបំផុតដើម្បីឈានទៅដល់ការយល់ដឹងយ៉ាងច្បាស់ជាងមុន និង ដ៏ទូលំទូលាយចំពោះបញ្ហាសុខភាពដែលពន្ធនាគារកម្ពុជាកំពុងតែជួបប្រទះនាពេលបច្ចុប្បន្ននេះ ។

## VIII- អនាម័យ និង ជំងឺឆ្លង

*(រាល់ការផ្តល់ការស្នាក់នៅដល់ពិរុទ្ធជននិងទណ្ឌិតទាំងឡាយ ជាពិសេសការផ្តល់កន្លែងទទួលទានដំណេក ត្រូវអោយសមស្របទៅតាមតម្រូវការរបស់សុខភាពត្រូវគិតពីលក្ខខណ្ឌអាកាសធាតុ និងជាពិសេស គិតពីចំណុះខ្យល់សំរាប់ដកដង្ហើម កំរិតអប្បរមានៃទំហំផ្ទៃអគារ ពន្លឺ កំដៅ និង បរិមាណខ្យល់ចេញ ចូល ។*

- ***បទបញ្ញត្តិជាបទដ្ឋានអប្បរមាសំរាប់អនុវត្តចំពោះអ្នកទោស***

*"ពន្ធនាគារនីមួយៗ ត្រូវមានអ្នកថែទាំងសុខភាព ដែលមានភារកិច្ចទទួលខុសត្រូវ :*

*-ពិនិត្យអនាម័យនៅក្នុងពន្ធនាគារយ៉ាងហោចណាស់អោយបាន៣ខែម្តងហើយត្រូវរាយការណ៍ជូនប្រធានពន្ធនាគារ និងប្រធាននាយកដ្ឋានក្នុងអម្លុងពេល ៧ថ្ងៃ "*

*"ពន្ធនាគារនីមួយៗ ត្រូវមានអ្នកថែទាំងសុខភាព ដែលមានភារកិច្ចទទួលខុសត្រូវ :*

*- ថែទាំសុខភាពអ្នកជាប់ពន្ធនាគារ*

*- ផ្តល់ជំនួយសង្គ្រោះបន្ទាន់ផ្នែកពេទ្យ និង*

*- ពិនិត្យសុខភាពអ្នកជាប់ពន្ធនាគារ" ។*

**-ប្រកាសលេខ ២១៧ ស្តីការគ្រប់គ្រងពន្ធនាគារ (១៩៩៨)**

*"អ្នកជាប់ពន្ធនាគារដែលមានលក្ខណ:ដូចខាងក្រោមត្រូវឃុំទុកក្នុងអគារតាមការអនុញ្ញាតដាច់ដោយឡែក គឺ: អ្នកជាប់ពន្ធនាគារណាដែលមានរោគសញ្ញា ជំងឺលើផ្លូវកាយ ឬផ្លូវចិត្ត ឬមានរបួស ដែលអាចប៉ះពាល់ដល់សុខភាពផ្ទាល់ខ្លួនរបស់គេ និង សុខមាលភាពរបស់អ្នកដទៃ "*

**- ប្រកាសលេខ ២១៧ ស្តីការគ្រប់គ្រងពន្ធនាគារ (១៩៩៨)**

ក្នុងចំណោមរោគវិនិច្ឆ័យរបស់អ្នកជាប់ពន្ធនាគារ[8] ទាំង ៥២៤៥ ប្រភេទ ដែលយើងបានពិនិត្យព្យាបាលក្នុងរយៈកាលកន្លងមក មានប្រមាណ ២.៥០២ (៤៧,៧ %) នៃរោគវិនិច្ឆ័យទាំងនេះគឺបណ្តាលមកពីជំងឺឆ្លង ។ លើសពីនេះទៅទៀត ប្រហែល២០% គឺជារោគដែលបណ្តាលមកពីបញ្ហាខ្វះអនាម័យ SRD ដូចជាជំងឺរាគរមាស់ ជំងឺប៉ារ៉ាស៊ីត និង គ្រុនពោះវៀនជាដើម ។ ការឆ្លងនៃជំងឺទាំងនេះគឺមានការពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងលក្ខខណ្ឌនៃការរស់នៅក្នុងពន្ធនាគារ ។

ការរាលដាលពាសពេញនៃជំងឺរមាស់មានលក្ខណៈធ្ងន់ធ្ងរយ៉ាងខ្លាំងនៅក្នុងពន្ធនាគារសព្វថ្ងៃនេះ ។ កាលពីខែ វិច្ឆិកា ឆ្នាំ ២០០១ កន្លងទៅនេះអង្គការលីកាដូបានធ្វើការសិក្សាស្រាវជ្រាវជាទូទៅមួយនៅពន្ធនាគារប៉េហ្ស៊ី និង ពន្ធនាគារតាខ្មៅ ខេត្តកណ្តាល ។ យោងតាមសំដីបុគ្គលិកក្នុងពេលសម្ភាសន៍នៅពន្ធនាគារទាំងនោះបានបញ្ជាក់ថាបញ្ហាអនាម័យនិងជំងឺរមាស់គឺជាបញ្ហាដ៏ចម្បងបំផុតនៅតាមបណ្តាពន្ធនាគារទាំងនោះ។

ការសិក្សាថ្មីៗ ដែលធ្វើនៅពន្ធនាគារតាខ្មៅកាលពីខែឧសភា ២០០២ បានបង្ហាញអោយឃើញថា មានអ្នកជាប់ពន្ធនាគារចំនួន ១០៩នាក់ (៣៧,៦%) បានបង្ហាញអោយឃើញនូវការឆ្លងជំងឺរមាស់ស្រាលៗ ឬ ស្នាមរមាស់ដែលមិនរាលដាល ។ ៣៧នាក់ទៀត (១២,៨%) បានបង្ហាញនូវភស្តុតាងនៃការឆ្លងរមាស់ធ្ងន់ធ្ងរ ឬ ឆ្លង

---

[8] *ចំនួនរោគវិនិច្ឆ័យអ្នកជាប់ពន្ធនាគារសរុបទាំងអស់ មិនជាប់ទាក់ទងគ្នាជាមួយនឹងចំនួនអ្នកជាប់ពន្ធនាគារ ដែលបានព្យាបាលទេ-ឧទាហរណ៍ អ្នកជាប់ពន្ធនាគារម្នាក់អាចមានរោគវិនិច្ឆ័យ ២ខុសគ្នា ។*

ពាសពេញខ្លួន ។ សរុបទាំងអស់ ១៤៦(៥០,៣%) ក្នុងចំណោមអ្នកជាប់ពន្ធនាគារចំនួន ២៩០ នាក់ នៅពន្ធនាគារតាខ្មៅក៏បានរងជំងឺឆ្លងនេះតាមបែបផ្សេងៗទៀតដែរ ។

***រូបទី ៥ : ភាគរយនៃអ្នកជាប់ពន្ធនាគារដែលឆ្លងជំងឺរមាស់ពាសពេញ (ពន្ធនាគារតាខ្មៅ ខែ ឧសភា ឆ្នាំ ២០០២)***




ការសិក្សាដូចគ្នានេះក៏បានអនុវត្តនៅពន្ធនាគារប៉ៃហ្ស៊ីនៅក្នុងខែឧសភាឆ្នាំ២០០២ នេះដែរហើយបានរកឃើញថាអ្នកជាប់ពន្ធនាគារចំនួន ១២នាក់ (១៨,៧%) បានបង្ហាញនូវភស្តុតាងឆ្លងជំងឺរមាស់ស្រាល ឬឆ្លងរមាស់ដែលមិនរាលដាលពាសពេញ ។ ចំណែក ៨នាក់ទៀត (១២,៨%) បានបង្ហាញនូវភស្តុតាងធ្ងន់ធ្ងរ ឬមានការឆ្លងជំងឺរមាស់ពាសពេញខ្លួន ។ សរុបទាំងអស់២០នាក់ (៣១,២%) នៃអ្នកជាប់ពន្ធនាគារទាំងអស់ ៦៤ នាក់ នៅពន្ធនាគារ ប៉ៃហ្ស៊ី ក៏បានទទួលរងការឆ្លងជំងឺរមាស់នេះតាមបែបផ្សេងៗទៀតដែរ ។

***រូបទី ៦ : ភាគរយនៃអ្នកជាប់ពន្ធនាគារដែលឆ្លងរមាស់ពាសពេញនៅប៉ៃហ្ស៊ី (ខែ ឧសភា ឆ្នាំ ២០០២ )***




បញ្ហាកង្វះអនាម័យនិងជំងឺមានសភាពកាន់តែធ្ងន់ធ្ងរឡើងៗដែលបណ្តាលមកពីបន្ទប់ឃុំឃាំងតូចចង្អៀតខ្លាំង ហើយអ្នកជាប់ពន្ធនាគារចេះតែកើតឡើងៗ ។ ចំនួនអ្នកជាប់ពន្ធនាគារសរុបនៅក្នុងពន្ធនាគារទាំង២០

បានកើនរហូតដល់ ៦៥% នៅក្នុងចន្លោះពេលពីខែធ្នូ ឆ្នាំ ១៩៩៨ មកដល់ ខែធ្នូ ឆ្នាំ២០០១ នេះ ។ ក្នុងកំឡុងពេលដូចគ្នានេះដែរ ចំនួនអ្នកជាប់ពន្ធនាគារសរុបនៅក្នុងពន្ធនាគារដែលបានពិនិត្យព្យាបាលដោយគ្រូពេទ្យលីកាដូក៏បានកើនដល់ ៣៦.៤ % ផងដែរ (រូប ៧) ។

### *រូបទី ៧: បំលាស់ប្តូរចំនួនអ្នកជាប់ពន្ធនាគារ-១៩៩៨ -២០០១*




អ្នកជាប់ពន្ធនាគារនៅតាខ្មៅ ១០០% និង អ្នកជាប់ពន្ធនាគារនៅប៉េហ្ស៊ី ២៥% មានទំហំបន្ទប់ឃុំឃាំងតូចជាងក៏រិតមធ្យមដែលកំណត់ដោយពន្ធនាគារជាតិនៅឆ្នាំ ១៩៩៤ ដែលទំហំនោះគឺ ២.៥ ម៉ែត្រការេក្នុងម្នាក់ ។ ស្ថានភាពពន្ធនាគារនៅតាខ្មៅមានភាពយ៉ាប់យ៉ឺនខ្លាំងណាស់ នៅទីនោះទំហំបន្ទប់ឃុំឃាំងសំរាប់អ្នកជាប់ពន្ធនាគារម្នាក់មានត្រឹមតែ ១.៣ម៉ែត្រការេប៉ុណ្ណោះ ហើយមានអ្នកជាប់ពន្ធនាគារ ១៤% ទៀតស្ថិតនៅក្នុងបន្ទប់ឃុំឃាំងតូចជាង ១ ម៉ែត្រការេទៅទៀត ។ ក្នុងករណីពុំមានដំណោះស្រាយជាបន្ទាន់នូវបញ្ហាចង្អៀតនេះ ការយកចិត្តទុកដាក់បញ្ហាអនាម័យអាចក្លាយជាកិច្ចការសំខាន់ជាងនេះទៅទៀតចំពោះសុខភាពអ្នកជាប់ពន្ធនាគារ ។

ជំងឺឆ្លង និងស្ថានភាពនៃការរស់នៅមានទំនាក់ទំនងគ្នាយ៉ាងខ្លាំង។ បើលើកយកបញ្ហាចង្អៀតខ្លាំងនិងកង្វះអនាម័យបច្ចុប្បន្ននៅពន្ធនាគារកម្ពុជា វាជាការមិនត្រូវភ្ញាក់ផ្អើលទេ ដែលជំងឺឆ្លងមានអត្រាភាគរយយ៉ាងខ្ពស់ក្នុងចំណោមជំងឺក្នុងពន្ធនាគារទាំងឡាយ ។ ដើម្បីដោះស្រាយបញ្ហានេះ ការិយាល័យពេទ្យបានចាប់ផ្តើមនូវកម្មវិធីអនាម័យសាកល្បងមួយនៅពន្ធនាគារនៅភ្នំពេញកាលពីខែមេសា ឆ្នាំ ២០០២ កន្លងទៅនេះ។ ផែនការនេះសំដៅដោះស្រាយបញ្ហាទូទៅ ចំណាយថវិកាតិច ខិតខំប្រឹងប្រែងដើម្បីព្យាបាលរមាស់ និងធ្វើអោយមានអនាម័យសាកល្បងរយៈពេល ៦ ខែ នៅពន្ធនាគារ ប៉េហ្ស៊ី និង តាខ្មៅ ។

**រូបថតទី ១ : ភាពចង្អៀតខ្លាំងនៃបន្ទប់ឃុំឃាំង**



*ពន្ធនាគារកម្ពុជាជាច្រើនកំពុងជួបប្រទះភាពចង្អៀតបែបនេះ  បណ្តាលអោយកើតមានការឆ្លងរាលដាលប៉ារ៉ាស៊ីត ដូចជារមាស់ និងជំងឺផ្សេងៗទៀតជាដើម ។*

**រូបថតទី ២: ការងារអនាម័យ**



*ដោយមានការចូលរួមជួយពីសំណាក់បុគ្គលិកថែទាំសុខភាពពន្ធនាគារ   អ្នកជាប់ពន្ធនាគារមានលទ្ធភាពសំអាតបន្ទប់ឃុំឃាំងរបស់ខ្លួនដោយប្រើឧបករណ៏ផ្តល់ដោយលីកាដូ  ។  ការយកចិត្តទុកដាក់លើបញ្ហាអនាម័យអោយ*

*បានខ្លាំង វាជាកត្តាសំខាន់ណាស់ក្នុងការការពារជំងឺឆ្លង ។ ហើយវាកាន់តែសំខាន់ថែមទៀតនៅពេលមានភាពចង្អៀតហួសហេតុកើតមាន ។*

**រូបថតទី៣: ការងារសុខភាពទូទៅ**



*ដោយមានការចូលរួមជួយពីសំណាក់គ្រូពេទ្យលីកាដូ អ្នកជាប់ពន្ធនាគារមានលទ្ធភាពស្ងោរសម្លៀកបំពាក់ និង មុង ភួយរបស់ពួកគេដើម្បីសំលាប់ប៉ារ៉ាស៊ីត ដូចជា រមាស់ ដែលជាជំងឺឆ្លងជាទូទៅនៅក្នុងពន្ធនាគារ ។*

**អនុសាសន៍:**

- រាជរដ្ឋាភិបាលកម្ពុជាត្រូវតែអនុវត្តនូវការប្រឹងប្រែងអោយអស់ពីលទ្ធភាពដើម្បីជួយកាត់បន្ថយនូវកំរិតចង្អៀតណែនខ្លាំងដែលកំពុងតែកើតមានក្នុងពន្ធនាគារកម្ពុជាសព្វថ្ងៃ ។ បញ្ហានេះតំរូវអោយមានការកសាងពន្ធនាគារថ្មីថែមទៀតឬពង្រីក កែលំអពន្ធនាគារដែលមានស្រាប់ដើម្បីអោយអ្នកជាប់ពន្ធនាគារម្នាក់ៗមានកន្លែងធំទូលាយជាងមុន ។
- បើយើងក្រលេកមើលកំណើនដ៏ខ្ពស់នៃចំនួនអ្នកជាប់ពន្ធនាគារប៉ុន្មានឆ្នាំថ្មីៗកន្លងទៅនេះរាជរដ្ឋាភិ-បាលកម្ពុជាត្រូវតែរៀបចំផែនការដើម្បីអោយអ្នកទោសចូលមកក្នុងពន្ធនាគារមានកន្លែងរស់នៅគ្រប់គ្រាន់ ជាជាងនៅតែបន្តដាក់យ៉ាងណែននៅក្នុងពន្ធនាគារដែលមានស្រាប់ ។

## IX- បញ្ហាកង្វះម្ហូបអាហារ : ជំងឺស្គីកនៅក្នុងពន្ធនាគារ

*អ្នកគ្រប់គ្រងពន្ធនាគារត្រូវតែផ្តល់អាហារដល់អ្នកជាប់ពន្ធនាគារនូវម្ហូបអាហារ :*

- *តាមម៉ោងពេលធម្មតា*
- *អាហារនោះត្រូវមានគុណភាព និងជីវជាតិល្អគ្រប់គ្រាន់សំរាប់សុខភាព និងកម្លាំងកាយ*
- *ជាអាហារដែលផ្តល់នូវសុខភាព*

*- ជាអាហារដែលត្រូវបានចំអិនត្រឹមត្រូវ ដោយយកចិត្តទុកដាក់ និង*

*- ធ្វើការចែកចាយអោយមានលក្ខណៈសមរម្យ ។*

**- បទបញ្ញត្តិជាបទដ្ឋានសំរាប់អនុវត្តចំពោះអ្នកជាប់ពន្ធនាគារ**

*អ្នកទោសគ្រប់រូបត្រូវបានគេផ្តល់ម្ហូបអាហារ ដែលមានជីវជាតិគ្រប់គ្រាន់ជារៀងរាល់ថ្ងៃ តាមរបបប្រចាំថ្ងៃ ដើម្បីទ្រទ្រង់សុខភាព និងសុខុមាលភាពរបស់ពួកគេ ។*

**-ប្រកាសលេខ ២១៧ ស្តីពីការគ្រប់គ្រងពន្ធនាគារ (១៩៩៨)**

អ្នកជាប់ពន្ធនាគារនៅកម្ពុជា ជាទូទៅពុំបានទទួលម្ហូបអាហារដែលមានសារជាតិចិញ្ចឹមគ្រប់គ្រាន់ទេ ។ ក្នុងករណីដែលអ្នកជាប់ពន្ធនាគារទាំងនោះខ្វះមធ្យោបាយក្នុងការរកម្ហូបអាហារមកបន្ថែម ជួនកាលវាបណ្តាលអោយមានការគំរាមកំហែងដល់អាយុជីវិតធ្ងន់ធ្ងរ ព្រមទាំងមានបញ្ហាសុខភាពច្រើនផង ។ ផលប៉ះពាល់ដោយសារកង្វះម្ហូបអាហារច្រើនតែបណ្តាលអោយគ្រោះថ្នាក់ធ្ងន់ធ្ងរ ហើយពិបាកក្នុងការកំណត់នូវកិរិតរបស់វាណាស់ យូរៗទៅរាងកាយនឹងត្រូវបាត់បង់នូវលទ្ធភាពក្នុងការទ្រទ្រង់ខ្លួនឯងព្រមទាំងងាយឆ្លងជំងឺ។ ប៉ុន្តែ ជួនកាលកង្វះម្ហូបអាហារក៏ជាមូលហេតុផ្ទាល់នៃជំងឺដែរ ឧទាហរណ៍ដូចជាជំងឺស្លឹកជាដើម ។

ស្លឹកជាជំងឺមួយដែលបណ្តាលអោយមានការចុះខ្សោយប្រព័ន្ធសរសៃប្រសាទ ប្រព័ន្ធរំលាយ និង បេះដូងកាន់តែខ្លាំងឡើងៗ ។ នៅក្នុងដំណាក់កាលឈឺធ្ងន់ជម្ងឺស្លឹកនេះបណ្តាលអោយមានការលំបាកក្នុងការដើរ ហើមធំហួសប្រមាណ បេះដូងចុះខ្សោយនិងអាចឈានដល់ស្លាប់ផង ។ជំងឺនេះទាក់ទងទៅនិងកង្វះលទ្ធភាពក្នុងការផ្លាស់ប្តូរជាតិកាបូអ៊ីដ្រាតអោយបានត្រឹមត្រូវ ហើយមូលហេតុបណ្តាលមកពីកង្វះជីវជាតិបេ១ ។ ជីវជាតិបេ១ ឬជួនកាលហៅថាធៀមីនជាធម្មតាមាននៅក្នុងដំបែរ អង្កាម និងកន្ទក់ ។ មានពន្ធនាគារខ្លះព្យាយាមយកកន្ទក់មកធ្វើជាម្ហូបអាហារសំរាប់អ្នកទោសតម្រូវអោយមានការផ្តល់ដល់អ្នកជាប់ពន្ធនាគារទាំងឡាយនូវម្ហូបអាហារអោយបានគ្រប់គ្រាន់ ។ ដើម្បីជួយអោយសំរេចបានតាមតំរូវការនេះ លីកាដូក៏បានជួយឧបត្ថម្ភជាប្រចាំនូវគ្រាប់ពូជបន្លែដល់ពន្ធនាគារមួយចំនួន ។ ជាមួយនឹងពូជបន្លែ និងសម្ភារៈទាំងនេះ អ្នកជាប់ពន្ធនាគារអាចបានម្ហូបអាហារបន្ថែមដោយការដាំបន្លែដោយខ្លួនឯង ។

**រូបថតទី ៤: អាហារ**



*អ្នកជាប់ពន្ធនាគារនៅតាខ្មៅដាំបន្លែដោយប្រើប្រាស់គ្រាប់ពូជដែលលីកាដូផ្តល់អោយដើម្បីផលិតម្ហូបអាហារបន្ថែម ។*

នៅក្នុងឆ្នាំដែលបានលើកឡើងកន្លងមកនេះគ្រូពេទ្យយើងបានធ្វើការព្យាបាលជំងឺស្ពឹកនេះរហូតដល់ទៅ ៤២៣ករណីនៅក្នុងចំណោមអ្នកជាប់ពន្ធនាគារទាំងឡាយ ។ ចំនួននេះស្មើនឹង ៨.១ % នៃរោគវិនិច្ឆ័យសរុបដែលមាននៅក្នុងកំឡុងពេលនោះ ហើយវាជារោគវិនិច្ឆ័យមួយដែលមានចំណាត់ថ្នាក់ទី ២ បន្ទាប់ពីជំងឺគ្រុនផ្តាសាយធំ ។ លើសពីនេះទៅទៀត និងជាពិសេសត្រូវកត់សំគាល់ថា រោគវិនិច្ឆ័យទី៦ គឺជំងឺដូចគ្នានិងជំងឺខ្វះជីវជាតិដែរដែលមានចំនួន២៦៧ករណី ។ នៅពេលដែលជំងឺខ្វះជីវជាតិទាំងពីរនេះរួមចូលគ្នាវាធ្វើអោយមានជំងឺម្យ៉ាងប្រហែលគ្នា និងផ្តាសាយធំដែរ ដែលជាជំងឺកើតច្រើនបំផុតក្នុងចំណោមអ្នកជាប់ពន្ធនាគារ ( មើលរូបទី ៨) ។

*រូបទី ៨: មូលហេតុសំខាន់ៗខ្លះៗនៃជំងឺអ្នកជាប់ពន្ធនាគារ*




**អនុសាសន៍ :**

- រាជរដ្ឋាភិបាលកម្ពុជាត្រូវតែផ្តល់ដល់អ្នកជាប់ពន្ធនាគារទាំងឡាយនូវៈ ម្ហូបអាហារដែលមានសារជាតិចិញ្ចឹមគ្រប់គ្រាន់ ដើម្បីអោយមានសុខភាព និងកម្លាំងកាយមាំមួនស្របទៅនឹងច្បាប់កម្ពុជា ។

## XI- កង្វះទឹកស្អាត

*" ទឹកសំរាប់ផឹកត្រូវតែមានសំរាប់អ្នកជាប់ពន្ធនាគារគ្រប់រូបនៅពេលដែលគេត្រូវការ"*

**- បទបញ្ញត្តិជាបទដ្ឋានអប្បរមាសំរាប់អនុវត្តចំពោះអ្នកទោស**

*" អ្នកជាប់ពន្ធនាគារទាំងឡាយត្រូវមានទឹកគ្រប់គ្រាន់ និង ស្អាតសំរាប់ផឹកគ្រប់ពេលវេលា "*

**- ប្រកាសលេខ ២១៧ ស្តីពីការគ្រប់គ្រងពន្ធនាគារ ( ១៩៩៨ )**

កង្វះទឹកដែលអាចផឹកបាននៅក្នុងពន្ធនាគារកម្ពុជាភាគច្រើនជាឧបសគ្គមួយផ្នែកធំដែរ ដែលរារាំងមិនអោយអ្នកជាប់ពន្ធនាគារមានសុខភាពប្រសើរបាន ។ មានភស្តុតាងជាក់ស្តែងខ្លះៗដែលទាក់ទងទៅនឹងបញ្ហា

គុណភាពទឹកផឹកនេះហើយកន្លងមកយើងសង្កេតឃើញថាមិនដែលមានពន្ធនាគារណាមួយក្នុងចំណោមពន្ធនាគារទាំងឡាយដែលយើងបំរើនោះបានធ្វើការពិសោធន៍ប្រភពទឹករបស់គេឡើយ ។ គ្រូពេទ្យអង្គការលីកាដូបានទទួលស្គាល់នូវសារៈសំខាន់នៃគុណភាពទឹកផឹកស្អាតដើម្បីអោយអ្នកទោសទាំងអស់មានសុខភាពល្អប្រសើរ ។ ស្របជាមួយគ្នានេះដែរ នៅក្នុងឆ្នាំ២០០២នេះ យើងបានមានផែនការដើម្បីធ្វើការពិសោធន៍ទឹកផឹកនៅក្នុងពន្ធនាគារដែលជាផ្នែកមួយនៃកម្មវិធីអនាម័យសាកល្បងរបស់យើង ។

កាលពីខែធ្នូ ឆ្នាំ ២០០១ ដោយមានកិច្ចសហការជាមួយវិទ្យាស្ថានប៉ាស្ទ័រ ការសិក្សាជាបឋមត្រូវបានអនុវត្តទៅលើគំរូទឹកផឹកដែលយកមកពីពន្ធនាគារ តាខ្មៅ និង ប៉េហ្ស៊ី ដែលទាក់ទងទៅនិងប្រព័ន្ធផ្គត់ផ្គង់ទឹកក្រុងភ្នំពេញ ហើយជាលទ្ធផលឃើញថាទឹកទាំងនោះជាទឹកស្អាត ។

នៅថ្ងៃអនាគតយើងសង្ឃឹមថានឹងទទួលបាននូវគុណភាពទឹកដែលស្របតាមបទដ្ឋានអាចជឿជាក់បាននៅតាមពន្ធនាគារកម្ពុជាតាមរយៈការធ្វើពិសោធន៍ជាប្រចាំ។ ពតិមាននេះនឹងទាមទារអោយយើងមានការប្រឹងប្រែងក្នុងការរកភស្តុតាងជាមូលដ្ឋាន ដើម្បីអនុវត្តរកដំណោះស្រាយសមរម្យមួយ។

**អនុសាសន៍:**

- ត្រូវចាត់វិធានការណ៍ជាជំហានៗដើម្បីធានាអោយមានទឹកគ្រប់គ្រាន់ និងមានគុណភាពល្អសំរាប់អ្នកជាប់ពន្ធនាគារគ្រប់រូប ។

## XI- អ្នកជាប់ពន្ធនាគារស្ត្រី : បញ្ហាសម្ភព និង រោគស្ត្រី

*" នៅក្នុងមន្ទីរឃុំឃាំងអ្នកជាប់ពន្ធនាគារជាស្ត្រី ត្រូវអោយមានការឧបត្ថម្ភពិសេសសំរាប់ថែរក្សា និងព្យាបាលខ្លួន នៅមុននិងក្រោយពេលសម្រាលកូន ។*

**-បទបញ្ញត្តិជាបទដ្ឋានអប្បបរមាសំរាប់អនុវត្តចំពោះអ្នកជាប់ពន្ធនាគារ**

"ចំពោះស្ត្រីជាប់ពន្ធនាគារដែលមានផ្ទៃពោះ:

- *ត្រូវផ្តល់កិច្ចឧបត្ថម្ភពិសេស ដើម្បីថែទាំសុខភាពស្ត្រីនោះ មុន និងក្រោយពេលសម្រាលកូន។*
- *ត្រូវអនុញ្ញាតអោយទៅសម្រាលកូននៅមន្ទីរពេទ្យខាងក្រៅពន្ធនាគារ ។*
- *បើសិនស្ត្រីជាប់ពន្ធនាគារណាសម្រាលកូននៅក្នុងពន្ធនាគារ អ្នកថែទាំសុខភាពម្នាក់ត្រូវចូលរួម*
- *ពិនិត្យសុខភាពម្តាយនិងកូននោះយ៉ាងឆាប់តាមដែលអាចធ្វើទៅបានបន្ទាប់ពីសម្រាលកូនរួច "។*

**-ប្រកាសលេខ ២១៧ ស្តីពីការគ្រប់គ្រងពន្ធនាគារ (១៩៩៨)**

នៅក្នុងឆ្នាំ ២០០១ គ្រូពេទ្យលីកាដូបានធ្វើការព្យាបាលរោគស្ត្រីចំនួន ៤៨១ ករណីក្នុងចំណោមអ្នក អ្នកជាប់ពន្ធនាគារជាស្ត្រីទាំងឡាយ ។ ដូចបានលើកឡើងពីខាងដើម ក្នុងចំណោមអ្នកជាប់ពន្ធនាគារដែលបាន ព្យាបាលទាំងអស់ក្នុងឆ្នាំ ២០០១ កន្លងទៅនេះ ចំនួនប្រមាណ ៧,៧ % ជាស្ត្រី (មើលរូប ទី ៣) ។

ការវិភាគមួយនៅក្នុងចំណោមរោគទាំងឡាយដែលកើតមានញឹកញាប់បំផុតក្នុងចំណោមស្ត្រីជាប់ពន្ធនាគារ (នៅក្នុងរូបទី ៩) គឺបង្ហាញអោយឃើញថា រោគចំនួន ២០ ប្រភេទដែលកើតមានច្រើនជាងគេនោះមានរហូតដល់ទៅប្រមាណ ៨៨,៩ % នៃរោគទាំងអស់ដែលកើតមានចំពោះស្ត្រីនៅក្នុងពន្ធនាគារ ។

នៅក្នុងឆ្នាំ ២០០១ កន្លងទៅនេះ បុគ្គលិកពេទ្យរបស់លីកាដូបានជួយក្នុងការចាត់ចែងរៀបចំដល់អ្នកជាប់ពន្ធនាគារស្ត្រីមានផ្ទៃពោះមួយចំនួន ។ ស្ត្រីជាប់ពន្ធនាគារទាំងនោះមានផ្ទៃពោះក្នុងខណៈពេលចូលមកដល់ពន្ធនាគារ ។ ប៉ុន្តែលីកាដូក៏បានរកឃើញថា មានស្ត្រីម្នាក់បានចាប់ផ្តើមមានផ្ទៃពោះក្នុងខណៈពេលដែលនាងនៅក្នុងពន្ធនាគាររួចហើយដែរ (*សូមអានទំព័របន្ទាប់-ផ្នែក ការរំលោភផ្លូវភេទក្នុងពន្ធនាគារ*) នេះជាករណីរំលោភផ្លូវភេទនៅក្នុងពន្ធនាគារមួយ ។

ចំណុចសំខាន់ដែលត្រូវកត់សម្គាល់ថា ជម្ងឺរលាកទ្វាមាសមានចំនួនដល់ទៅ ៥,០% នៃរោគវិនិច្ឆ័យទាំងឡាយដែលកើតមានចំពោះស្ត្រីជាប់ពន្ធនាគារ ។ រលាកទ្វារមាសជាកន្សោមពាក្យមួយដែលពិពណ៌នាពីការរលាកនៃទ្វារយោនីរបស់ស្ត្រីរួមទាំងការធ្លាក់សផង ។ ដូច្នេះជម្ងឺរលាកទ្វារមាសក៏អាចបណ្តាលមកពីមូលហេតុផ្សេងៗគ្នាដែរ ដូចជា បាក់តេរី ផ្សិត ប្រតិកម្មនឹងអ្វីមួយ (*អាលែកហ្ស៊ី*) អ័រម៉ូន ។ល។ តាមការពិសោធន៍របស់យើងកន្លងមកជំងឺប្រភេទនេះជាធម្មតាទាក់ទងទៅនឹងការឆ្លងជំងឺនៅក្នុងពន្ធនាគារតែម្តង ។ ដូច្នេះជំងឺនេះវាជាជំងឺឆ្លងដែលកើតជាទូទៅបំផុតដែលជាប់ចំណាត់ថ្នាក់ទី២ បន្ទាប់ពីផ្តាសាយធំនៅក្នុងចំណោមជំងឺអ្នកជាប់ពន្ធនាគារទាំងអស់ ។

**រូបថតទី ៥: ទារកក្នុងពន្ធនាគារ**



*ស្ត្រីជាប់ពន្ធនាគារកំពុងបីទារកទើបកើត*

### *រូបទី ៩ : រោគវិនិច្ឆ័យសំខាន់ៗចំនួន ២០ ប្រភេទក្នុងចំណោមស្ត្រីជាប់ពន្ធនាគារ*

| ប្រភេទរោគ | ចំនួនរោគវិនិច្ឆ័យនៃអ្នកជាប់ពន្ធនាគារស្ត្រី | % |
|---|---|---|
| ផ្តាសសាយធំ | ៨៧ | ១៨.១ |
| ឈឺក្បាល | ៦៨ | ១៤.១ |
| ខ្វះជីវជាតិ ( ទូទៅ) | ៥៤ | ១១.២ |
| ជំងឺរលាកសរសៃប្រសាទ | ៣៤ | ៧.១ |
| មិនរំលាយអាហារ | ២៧ | ៥.៦ |
| រលាកក្រពះ | ២៤ | ៥.០ |
| រោគស្ត្រី( រលាកទ្វារមាស) | ២៤ | ៥.០ |
| រលាកសួត | ១៥ | ៣.១ |
| រាគរុះ | ១២ | ២.៥ |
| ព្រូនក្នុងពោះវៀន | ១២ | ២.៥ |
| ជំងឺលើសឈាម | ៩ | ១.៩ |
| រលាកបំពង់នោម | ៨ | ១.៧ |
| រលាកច្រមុះ | ៨ | ១.៧ |
| ឈឺសាច់ដុំ | ៨ | ១.៧ |
| មានផ្ទៃពោះ | ៧ | ១.៥ |
| បូស | ៧ | ១.៥ |
| រលាកទងសួត | ៧ | ១.៥ |
| រោគមួលដោយសារអាមីប | ៦ | ១.២ |
| គ្រុនពោះវៀន | ៥ | ១.០ |
| ឈឺសន្លាក់ដៃ ជើង | ៥ | ១.០ |
| **សរុប** | **៤២៧** | **៨៨.៩** |

**អនុសាសន៏:**

- ត្រូវផ្តល់ការថែទាំសុខភាពដល់ស្ត្រីមានផ្ទៃពោះដែលជាប់ពន្ធនាគារនៅមុននិងក្រោយពេលសម្រាលកូនអោយបានគ្រប់គ្រាន់ ស្របតាមច្បាប់កម្ពុជា ។

- គួរតែផ្តល់ការហ្វឹកហ្វឺនផ្នែកថែទាំ និងគ្រប់គ្រងអនាម័យអោយបានសមរម្យ និងកិច្ចការសុខភាពផ្សេងៗទៀតដែលទាក់ទងទៅនឹងស្ត្រីជាប់ពន្ធនាគារដល់បុគ្គលិកថែទាំសុខភាពពន្ធនាគារទាំងឡាយ ។ បើពុំមានអ្នកជំនាញបែបនេះទេ ត្រូវបញ្ជូនទៅមណ្ឌលសុខភាពដែលមានសមត្ថភាពជំនាញផ្នែកនេះជាបន្ទាន់ ។

## XII- ការរំលោភផ្លូវភេទក្នុងពន្ធនាគារ

*" នៅក្នុងពន្ធនាគារដែលមានទាំងបុរសនិងស្ត្រី ផ្នែកឃុំឃាំងស្ត្រីត្រូវដាក់អោយនៅក្រោមការគ្រប់គ្រងនៃភ្នាក់ងារមានសមត្ថកិច្ចជាស្ត្រីភេទ ដែលជាអ្នកកាន់កូនសោរបន្ទប់ឃុំឃាំងគ្រប់ផ្នែកទាំងអស់ ។"*

*" ហាមបុគ្គលិកភេទប្រុសចូលទៅក្នុងបន្ទប់ឃុំឃាំងរបស់ស្ត្រីនឹងអាចធ្វើទៅបានប្រសិនបើមានការអមដំណើរដោយមន្ត្រីពន្ធនាគារជាស្ត្រីភេទផង ។"*

**- បទបញ្ញត្តិជាបទដ្ឋានអប្បរមាសំរាប់អនុវត្តចំពោះអ្នកទោស**

*" បុគ្គលិក ឬមន្ត្រីពន្ធនាគារជាស្ត្រី ត្រូវតែអមដំណើរមន្ត្រីពន្ធនាគារជាបុរសនៅពេលចូលទៅក្នុងអគារ ឬបន្ទប់ឃុំឃាំងរបស់អ្នកជាប់ពន្ធនគារជាស្ត្រី ។ "*

**-ប្រកាសលេខ ២១៧ ស្តីការគ្រប់គ្រងពន្ធនាគារ (១៩៩៨)**

ការរំលោភសេពសន្ថវៈនិងការបង្ខិតបង្ខំលើស្ត្រីជាប់ឃុំឃាំងក្នុងពន្ធនាគារកម្ពុជាទាំងឡាយនៅជាបញ្ហាសុខភាពដ៏ចម្បងនៅឡើយ ។ ករណីសិក្សាខាងក្រោមជាការបញ្ជាក់អោយឃើញនូវឧទាហរណ៍ថ្មីៗ ។

### ករណីសិក្សាទី ២

កាលពីខែ វិច្ឆិកា ឆ្នាំ ២០០១ កន្លងទៅនេះ អង្គកាលីកាដូបានធ្វើការស៊ើបអង្កេតករណីអ្នកទោសស្ត្រីម្នាក់នៅក្នុងពន្ធនាគារ ម២ ។ នៅក្នុងពេលនោះនាងបានមានផ្ទៃពោះចំនួន ៧ ខែ តាមការពិតនាងត្រូវបានជាប់ពន្ធនាគារតាំងពីឆ្នាំ១៩៩៥មកម្ល៉េះ ។ យោងតាមសំដីរបស់អ្នកទោសនោះបានអោយដឹងថា នាងធ្លាប់បានរួមរ័ក្សជាមួយអ្នកយាមពន្ធនាគារពីរ-បីដងនៅពេលចូលឆ្នាំខ្មែរក្នុងឆ្នាំនោះ ។ ខាងក្រោមនេះគឺជាការរៀបរាប់របស់នាងអោយយើងបានដឹងថា:

នៅវេលាម៉ោង ១០ ព្រឹកនៅថ្ងៃចូលឆ្នាំខ្មែរ ថ្ងៃទីមួយនាងបានចូលបង្គន់ ។ នៅពេលចេញពីបង្គន់វិញនាងបានជួបនិងអ្នកយាមពន្ធនាគារ ហើយបានប្រាប់អោយនាងចូលទៅក្នុងបន្ទប់ទឹកនោះវិញជាមួយគាត់ ។ នៅពេលនោះនាងនិយាយថា នាងស្រវឹងបន្តិចបន្តួច (ក្នុងកំឡុងពេល ចូលឆ្នាំ គេបានអោយស្រាដល់អ្នកជាប់ពន្ធនាគារផឹក) ។ ជាយថាហេតុ នាងក៏យល់ព្រមចូលទៅក្នុងបន្ទប់ទឹកនោះជាមួយគាត់ ។ ពេលចូលទៅដល់ក្នុងបន្ទប់ទឹកអ្នកយាមនោះបានប្រាប់នាងថា គាត់ចង់រួមរ័ក្សជាមួយនាង ។ ភ្លាមនោះនាងបានបដិសេធមិន

ព្រមទេ ប៉ុន្តែអ្នកយាមនោះនៅតែទទូចដដែល១ហើយអះអាងថា បើមានបញ្ហាអ្វីកើតឡើងគាត់ទទួលខុសត្រូវទាំងអស់ ។

នៅរសៀលថ្ងៃដដែលនោះ អ្នកយាមនោះបានប្រាប់អោយនាងទៅបន្ទប់ទឹកដែលជាកន្លែងគេធ្លាប់រួមរ័ក្សនោះម្តងទៀត ។ នៅថ្ងៃទីបីនៃឱកាសចូលឆ្នាំនោះ អ្នកយាមនោះក៏បានប្រាប់អោយនាងដើរតាមគាត់ទៅបន្ទប់ទឹកដើម្បីរួមរ័ក្សម្តងទៀត ។ រាល់ពេលនាងតែងតែព្យាយាមបដិសេធរហូត ប៉ុន្តែអ្នកយាមនោះនៅតែទទូចដដែល១ជាច្រើនដង ។

ជាលទ្ធផលចុងក្រោយ អ្នកទោសនោះក៏មានផ្ទៃពោះនៅពេលដឹងរឿងនេះ អ្នកយាមនោះបានយកថ្នាំដែលនាងមិនស្គាល់ថាជាថ្នាំអ្វីមកអោយនាង ហើយប្រាប់នាងដោយទទូចថា នាងត្រូវតែលេបវាដើម្បីទំលាក់គភ៌ ។ នាងបានលេបថ្នាំនោះ ប៉ុន្តែមិនមានលទ្ធផលល្អទេ ។

ក្នុងពេលសំភាសន៍ នាងបាននិយាយដោយក្តីបារម្ភថា នៅពេលសម្រាលកូននាងនឹងជួបការលំបាកច្រើន ពីព្រោះនាងមិនមានថវិកា ហើយអ្នកយាមនោះក៏បានបាត់ដំណឹងមិនដឹងទៅណាបាត់ដែរ ក្នុងពេលនោះ។ នាងបាននិយាយថា នាងមិនបានឃើញគាត់ប្រមាណជាងមួយខែមកហើយ ។

ករណីនេះបានបង្ហាញអោយឃើញយ៉ាងច្បាស់នូវភាពជាអ្នកងាយរងគ្រោះបំផុតចំពោះស្ត្រីដែលជាអ្នកជាប់នៅក្នុងពន្ធនាគារកម្ពុជា ។ ការពិតគឺឧប្បត្តិហេតុនេះបានកើតឡើងនៅក្នុងពន្ធនាគារដែលសំរាប់ដាក់តែស្ត្រីតែមួយគត់ហើយវាជាភស្តុតាងថែមទៀតដែលបញ្ជាក់ពីការខ្វះខាតក្នុងការដោះស្រាយបញ្ហាទាំងនេះអោយបានត្រឹមត្រូវនៅក្នុងពន្ធនាគារ ។

នៅពេលដែលមានស្ត្រីជាប់ពន្ធនាគារត្រូវបានគេបង្ខំអោយធ្វើការរួមរ័ក្សបែបនេះ វាបណ្តាលអោយសុខភាពរបស់នាងទាំងផ្លូវកាយ និងផ្លូវចិត្តត្រូវទទួលរងនូវគ្រោះថ្នាក់ ។ នៅក្នុងករណីពិភាក្សាខាងលើអ្នកជាប់ពន្ធនាគារត្រូវបានបន្សល់ទុកនូវការមានគភ៌មួយដែលមិនបានគ្រោងទុកជាមុន ហើយជារឿងមួយដែលមិនបានគ្រោងអោយកើតមានឡើងផង។ ក្នុងរឿងនេះនាងក៏អាចរងគ្រោះថ្នាក់ពីការឆ្លងជំងឺកាមរោគផងដែរ ។

**អនុសាសន៍:**

- ត្រូវការពារស្ត្រីជាប់ពន្ធនាគារពីគ្រប់ទំរង់នៃការរំលោភផ្លូវភេទគ្រប់ពេលវេលា ។
- ស្របតាមច្បាប់កម្ពុជា ស្ត្រីជាប់ពន្ធនាគារទាំងអស់ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចគ្រប់គ្រងរបស់បុគ្គលិកជាស្ត្រីភេទដូចគ្នា ។

## XIII. បុគ្គលិកពន្ធនាគារ

នៅក្នុងឆ្នាំ ២០០១ ការិយាល័យពេទ្យលីកាដូបានបន្តនូវគោលនយោបាយពង្រីកសេវាសុខភាពរបស់ខ្លួន ដើម្បីជួយព្យាបាលបុគ្គលិកពន្ធនាគារផងដែរ ។ នៅក្នុងឆ្នាំ២០០១ នេះគ្រូពេទ្យយើងបានពិនិត្យព្យាបាលរោគបុគ្គលិកពន្ធនាគារចំនួន ១៣០៦ ករណីក្នុងចំណោមបុគ្គលិកទាំងឡាយ ។

## XIV- សេចក្តីសន្និដ្ឋាន

អ្នកជាប់ពន្ធនាគារជាច្រើនដែលកំពុងត្រូវបានឃុំឃាំងក្នុងពន្ធនាគារកម្ពុជាបច្ចុប្បន្ន កំពុងតែរងគ្រោះពីសំណាក់ជំងឺដែលអាចការពារបាន ហើយដែលមិនគួររងគ្រោះទាល់តែសោះ ដោយបណ្តាលមកពីលទ្ធផលមួយភាគធំគឺលក្ខខណ្ឌនៃការរស់នៅមិនសមស្របនៃការឃុំឃាំងនោះ ។ តាមទិន្នន័យដែលបានបង្ហាញរួចមកហើយបានអោយដឹងថា១៣,៣%នៃរោគវិនិច្ឆ័យដែលបានរកឃើញក្នុងឆ្នាំ២០០១កន្លងទៅនេះ គឺជារោគដែលបណ្តាលមកពីកង្វះជីវជាតិ និងកង្វះម្ហូបអាហារ ។ ត្រង់ចំណុចនេះ ក្នុងច្បាប់កម្ពុជាក៏បានចែងយ៉ាងច្បាស់ផងដែរថា អ្នកជាប់ពន្ធនាគារគ្រប់រូបមានសិទ្ធិក្នុងការទទួលនូវម្ហូបអាហារដែលមានសារជាតិចិញ្ចឹម ព្រមទាំងជីវជាតិគ្រប់គ្រាន់ ។ រោគវិនិច្ឆ័យ ២០%ទៀត ដែលរកឃើញក្នុងឆ្នាំ ២០០១ នេះដែរគឺជារោគបណ្តាលមកពីកង្វះអនាម័យ និង ភាពចង្អៀតខ្លាំងដែលកើតមាននៅក្នុងពន្ធនាគារ ។ ប៉ុន្តែ វាជាការសមហេតុផលដែរ បើយើងប្រមាណមើលទៅ ថាករិតជំងឺនៅក្នុងពន្ធនាគារកម្ពុជាអាចថយចុះដល់មួយភាគបី ( ៣៣,៣ % ) តាមរយៈការខិតខំប្រឹងប្រែងសំអាតអនាម័យ កាត់បន្ថយភាពចង្អៀតខ្លាំង មានអគារឃុំឃាំងល្អជាងនេះ និង ផ្តល់ម្ហូបអាហារប្រកបដោយសារជាតិចិញ្ចឹមគ្រប់គ្រាន់សំរាប់អ្នកជាប់ពន្ធនាគារ ដែលអនុលោមទៅតាមច្បាប់របស់កម្ពុជានោះ ។

ទោះបីជាស្ត្រីមានចំនួនតិចមែននៅក្នុងចំណោមអ្នកជាប់ពន្ធនាគារទាំងអស់ ប៉ុន្តែវាជាការពិតណាស់ដែលតម្រូវការសុខភាពរបស់ស្ត្រីមានភាពខុសគ្នាពីតម្រូវការសុខភាពរបស់បុរស ។ វាតំរូវអោយមានសេវាផ្នែកសម្ភពនិងការពិនិត្យព្យាបាលរោគស្ត្រីអោយបានប្រសើរជាងនេះ ។ លើសពីនេះទៅទៀត ការរំលោភផ្លូវភេទក៏នៅជាបញ្ហាសុខភាពមួយ ដែលគួរអោយបារម្ភខ្លាំងណាស់ដែរ ។ តំរូវអោយមានការប្រឹងប្រែងថែមទៀត ដើម្បីការពារស្ត្រីជាប់ពន្ធនាគារពីសំណាក់ឆ្មាំពន្ធនាគារ ឬអ្នកជាប់ពន្ធនាគារដែលចូលចិត្តកេងយកចំណេញពីស្ត្រីៗទាំងនោះ ។

## XV- អនុសាសន៍សង្ខេប

**<u>លទ្ធភាពក្នុងការទទួលការថែទាំងសុខភាព</u>** ( ទំព័រ ១០)

១- រាជរដ្ឋាភិបាលកម្ពុជាត្រូវតែធានាអោយមានការថែទាំសុខភាពគ្រប់គ្រាន់ និង សមរម្យសំរាប់អ្នកជាប់ពន្ធនាគារគ្រប់រូបដែលជាប់ឃុំឃាំងក្នុងពន្ធនាគារកម្ពុជាស្របទៅតាមច្បាប់របស់កម្ពុជា ។

**អនាម័យនិងជំងឺឆ្លង** ( ទំព័រ ១៤)

២- រាជរដ្ឋាភិបាលកម្ពុជាត្រូវតែអនុវត្តនូវការប្រឹងប្រែងអោយអស់ពីលទ្ធភាព ដើម្បីជួយកាត់បន្ថយនូវកំរិតចង្អៀតណែនខ្លាំងដែលកំពុងតែកើតមានក្នុងពន្ធនាគារកម្ពុជាសព្វថ្ងៃ ។ បញ្ហានេះតំរូវអោយមានការកសាងពន្ធនាគារថ្មីថែមទៀតឬពង្រីក កែលំអពន្ធនាគារដែលមានស្រាប់ ដើម្បីអោយអ្នកជាប់ពន្ធនាគារម្នាក់ៗមានកន្លែងធំទូលាយជាងមុន។

៣- បើយើងក្រឡេកមើលកំណើនដ៏ខ្ពស់នៃចំនួនអ្នកជាប់ពន្ធនាគារប៉ុន្មានឆ្នាំថ្មីៗកន្លងទៅនេះ រាជរដ្ឋាភិបាលកម្ពុជាត្រូវតែរៀបចំផែនការ ដើម្បីអោយអ្នកទោសចូលមកក្នុងពន្ធនាគារមានកន្លែងរស់នៅគ្រប់គ្រាន់ជាជាងនៅតែបន្តដាក់យ៉ាងណែននៅក្នុងពន្ធនាគារដែលមានស្រាប់។

**កង្វះម្ហូបអាហារនិង ជំងឺស្លឹកក្នុងពន្ធនាគារ** ( ទំព័រ ១៩)

៤- រាជរដ្ឋាភិបាលកម្ពុជាត្រូវតែផ្តល់ដល់អ្នកជាប់ពន្ធនាគារទាំងឡាយនូវៈម្ហូបអាហារដែលមានសារជាតិចិញ្ចឹមគ្រប់គ្រាន់ ដើម្បីអោយមានសុខភាព និង កម្លាំងកាយមាំមួនស្របទៅនឹងច្បាប់កម្ពុជា ។

**កង្វះទឹកស្អាត** ( ទំព័រ ២០)

៥- ត្រូវចាត់វិធានការជាជំហានៗ ដើម្បីធានាអោយមានទឹកគ្រប់គ្រាន់ និង មានគុណភាពល្អសំរាប់អ្នកជាប់ពន្ធនាគារគ្រប់រូប ។

**អ្នកជាប់ពន្ធនាគារជាស្ត្រី : សម្ភព និងរោគស្ត្រី** ( ទំព័រ ២១)

៦- ត្រូវផ្តល់ការថែទាំងសុខភាពដល់ស្ត្រីមានផ្ទៃពោះដែលជាប់ពន្ធនាគារនៅមុន និង ក្រោយពេលសម្រាលកូនអោយបានគ្រប់គ្រាន់ស្របតាមច្បាប់កម្ពុជា។

៧- គួរតែផ្តល់ការហ្វឹកហ្វឺនក្នុងការថែទាំ និង គ្រប់គ្រងអនាម័យអោយបានសមរម្យនិងកិច្ចការសុខភាពផ្សេងៗទៀតដែលទាក់ទងទៅនឹងស្ត្រីជាប់ពន្ធនាគារដល់បុគ្គលិកថែទាំសុខភាពពន្ធនាគារទាំងឡាយ ។ បើពុំមានអ្នកជំនាញបែបនេះទេត្រូវបញ្ជូនទៅមណ្ឌលសុខភាពដែលមានសមត្ថភាពជំនាញផ្នែកនេះជាបន្ទាន់។

**ការរំលោភផ្លូវភេទក្នុងពន្ធនាគារ** ( ទំព័រ ២៣)

៨- ត្រូវការពារស្ត្រីជាប់ពន្ធនាគារពីគ្រប់រូបភាពនៃការរំលោភផ្លូវភេទគ្រប់ពេលវេលា ។

៩- ស្របតាមច្បាប់កម្ពុជា ស្ត្រីជាប់ពន្ធនាគារទាំងអស់ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចគ្រប់គ្រងរបស់បុគ្គលិកជាស្ត្រីភេទដូចគ្នា ។

## ឧបសម្ព័ន្ធ ក : ស្ថិតិរោគវិនិច្ឆ័យសរុបឆ្នាំ ២០០១

| រោគវិនិច្ឆ័យ | អ្នកជាប់ពន្ធនាគារ | | សរុប | អ្នកយាម | | សរុប |
|---|---|---|---|---|---|---|
| ជម្ងឺផ្នែកបេះដូង- សរសៃឈាម | ប្រុស | ស្រី | | ប្រុស | ស្រី | |

| | | | | | | |
|---|---|---|---|---|---|---|
| ជម្ងឺលើសឈាម | ១៦៤ | ៩ | ១៧៣ | ១៤ | ៤ | ១៨ |
| ជំងឺបេះដូងដើរខុសចង្វាក់ | ០ | ០ | ០ | ០ | ០ | ០ |
| ជម្ងឺឈាមចុះ | ១០ | ០ | ១០ | ០ | ១ | ១ |
| **សរុប** | **១៧៤** | **៩** | **១៨៣** | **១៤** | **៥** | **១៩** |
| **ជម្ងឺប្រអប់មាត់ និង ធ្មេញ** | | | | | | |
| ជង្គូវស៊ីធ្មេញ | ២០ | ០ | ២០ | ៤ | ១ | ៥ |
| រលាកអញ្ចាញធ្មេញ | ១០ | ០ | ១០ | ៤ | ០ | ៤ |
| ឈឺធ្មេញ | ២៩ | ២ | ៣១ | ១៣ | ១ | ១៤ |
| រលាកអណ្តាត | ២ | ០ | ២ | ០ | ០ | ០ |
| រលាកជុំវិញបបូរមាត់ | ២១ | ១ | ២២ | ៧ | ០ | ៧ |
| **សរុប** | **៨២** | **៣** | **៨៥** | **២៨** | **២** | **៣០** |
| **ជំងឺស្បែក** | | | | | | |
| រមាស់ | ១៦០ | ១ | ១៦១ | ១១ | ០ | ១១ |
| រើម | ៣ | ០ | ៣ | ០ | ០ | ០ |
| កន្ទួលក្រហមលើស្បែក | ៤ | ១ | ៥ | ១ | ០ | ១ |
| ស្រែង | ១៤៦ | ៣ | ១៤៩ | ២៧ | ០ | ២៧ |
| របួស | ៦ | ០ | ៦ | ២ | ០ | ២ |
| ជំងឺសើស្បែក | ៦៣ | ២ | ៦៥ | ១៣ | ១ | ១៤ |
| មុន | ០ | ០ | ០ | ១០ | ០ | ១ |
| រលាកស្បែក ( ក្រហម) | ៧ | ០ | ៧ | ០ | ០ | ០ |
| **សរុប** | **៣៨៩** | **៧** | **៣៩៦** | **៩៥** | **១** | **៩៦** |
| **ជម្ងឺខ្វិន** | | | | | | |
| ខ្វិនដោយការវាយដំ | ៦ | ០ | ៦ | ១ | ០ | ១ |
| ខ្វិនដោយគ្រាប់កាំភ្លើង | ៨ | ០ | ៨ | ០ | ០ | ០ |
| ខ្វិនដោយគ្រោះថ្នាក់ | ១ | ០ | ១ | ១ | ០ | ១ |
| **សរុប** | **១៥** | **០** | **១៥** | **២** | **០** | **២** |
| **ជម្ងឺផ្នែកត្រចៀក ច្រមុះ បំពង់ក** | | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| រោគរលាកបំពង់ក | **៩៩** | **៤** | **៦៣** | **២៤** | **១** | **២៥** |
| រលាកបំពង់ខ្យល់ | ០ | ០ | ០ | ៤ | ០ | ៤ |
| រលាកត្រចៀកផ្នែកខាងក្នុង | ៣៦ | ១ | ៣៧ | ៤ | ០ | ៤ |
| រលាកត្រចៀកផ្នែកខាងក្រៅ | ២ | ០ | ២ | ០ | ០ | ០ |
| រលាកសាច់បំពង់ក | ១៤ | ០ | ១៤ | ៣ | ១ | ៤ |
| រលាកឆ្អឹងក្តោងច្រមុះ | ៨ | ២ | ១០ | ០ | ០ | ០ |
| **សរុប** | **១១៩** | **៧** | **១២៦** | **៣៥** | **២** | **៣៧** |
| **ជម្ងឺផ្នែកក្រពះ ពោះវៀន** | | | | | | |
| រាគ | ១៤៧ | ១២ | ១៥៩ | ២៦ | ២ | ២៨ |
| ឫសដូងបាត | ៦១ | ០ | ៦១ | ៤ | ០ | ៤ |
| រលាកក្រពះ | ២៦៥ | ២៤ | ២៨៩ | ៨៥ | ៣ | ៨៨ |
| ខ្លួន | ១០ | ១ | ១១ | ០ | ០ | ០ |
| ពុលចំណីអាហារ | ៦ | ០ | ៦ | ០ | ០ | ០ |
| រលាកពោះវៀនធំ | ៤៨ | ៣ | ៥១ | ២ | ១ | ៣ |
| រោគមូល | ៧២ | ៦ | ៧៨ | ១៣ | ១ | ១៤ |
| ដំបៅក្រពះ | ៧ | ១ | ៨ | ០ | ០ | ០ |
| មិនរំលាយអាហារ | ២៧៧ | ២៧ | ៣០៤ | ៨៧ | ៦ | ៩៣ |
| **សរុប** | **៨៩៣** | **៧៤** | **៩៦៧** | **២១៧** | **១៣** | **២៣០** |
| **ជម្ងឺផ្នែកបន្តពូជ និងផ្លូវទឹកនោម** | | | | | | |
| ស្បែកដុះបិទចុងលិង្គ | ៣ | ០ | ៣ | ០ | ០ | ០ |
| រលាកតម្រងនោម | ៤ | ០ | ៤ | ២ | ០ | ២ |
| គ្រួសក្នុងប្លោកនោម | ២ | ០ | ២ | ០ | ០ | ០ |
| រលាកប្លោកនោម | ១៦ | ០ | ១៦ | ២ | ០ | ២ |
| រលាកបំពង់នោម | ៩១ | ៨ | ៩៩ | ២១ | ២ | ២៣ |
| **សរុប** | **១១៦** | **៨** | **១២៤** | **២៥** | **២** | **២៧** |
| **រោគស្ត្រី និង សម្ភព** | | | | | | |
| រលាកទ្វារមាស | ០ | ២៤ | ២៤ | ០ | ២ | ២ |

| | | | | | | |
|---|---|---|---|---|---|---|
| រដូវមិនទៀង | ០ | ១ | ១ | ០ | ០ | ០ |
| រលាកកស្បូន | ០ | ៣ | ៣ | ០ | ១ | ១ |
| រំលូតកូន | ០ | ០ | ០ | ០ | ០ | ០ |
| សម្រាលកូន | ០ | ០ | ០ | ០ | ១ | ១ |
| មានផ្ទៃពោះ | ០ | ៧ | ៧ | ០ | ០ | ០ |
| កង្វះជីវជាតិពេលមានផ្ទៃពោះ | ០ | ០ | ០ | ០ | ១ | ១ |
| **សរុប** | **០** | **៣៥** | **៣៥** | **០** | **៥** | **៥** |
| **ជម្ងឺគ្រាប់ឈាម** | | | | | | |
| ស្លេកស្លាំងដោយខ្វះឈាម | ១៩ | ០ | ១៩ | ២ | ០ | ២ |
| រលាកកូនកណ្ដុរ | ៩ | ០ | ៩ | ០ | ០ | ០ |
| ហើមកូនកណ្ដុរ | ១ | ០ | ១ | ០ | ០ | ០ |
| មហារីកដុំឈាម( ស្រាល) | ០ | ០ | ០ | ០ | ០ | ០ |
| ម្រេញ | ០ | ០ | ០ | ០ | ០ | ០ |
| **សរុប** | **២៩** | **០** | **២៩** | **២** | **០** | **២** |
| **ជម្ងឺរលាកថ្លើម និង ប្រមាត់** | | | | | | |
| រលាកថ្លើម | ២ | ០ | ២ | ៤ | ០ | ៤ |
| ថ្លើមខ្សោយ | ១ | ០ | ១ | ០ | ០ | ០ |
| រលាកថង់ប្រមាត់ | ០ | ០ | ០ | ០ | ០ | ០ |
| **សរុប** | **៣** | **០** | **៣** | **៤** | **០** | **៤** |
| **ជំងឺប្រតិកម្ម អាលែកហ្ស៊ី** | | | | | | |
| រលាកច្រមុះ | ២១ | ៨ | ២៩ | ១៣ | ៣ | ១៦ |
| ត្រអក | ៩ | ០ | ៩ | ៤ | ០ | ៤ |
| កន្ទាលត្រអាក | ៣ | ០ | ៣ | ២ | ១ | ៣ |
| ប្រតិកម្មស្បែក( កន្ទួលក្រហម) | ៤២ | ៣ | ៤៥ | ២៣ | ១ | ២៤ |
| **សរុប** | **៧៥** | **១១** | **៨៦** | **៤២** | **៥** | **៤៧** |
| **ប៉ារ៉ាស៊ីត និង រលាក** | | | | | | |
| បូស | ៨៣ | ៧ | ៩០ | ២៤ | ២ | ២៦ |

| | | | | | | |
|---|---|---|---|---|---|---|
| រាគមួល (Bacilary) | ១ | ០ | ១ | ១ | ០ | ១ |
| ផ្តាសសាយធំ | ៦៥៥ | ៨៧ | ៧៤២ | ៣២១ | ១៦ | ៣៣៧ |
| ព្រូន | ៥៦ | ១២ | ៦៨ | ៣៤ | ២ | ៣៦ |
| ដំបៅក្លាយ | ១២៧ | ៣ | ១៣០ | ១៣ | ០ | ១៣ |
| គ្រុនពោះវៀន | ៩៣ | ៥ | ៩៨ | ៥ | ២ | ៧ |
| ជំងឺវីរុស | ៣ | ០ | ៣ | ៤ | ០ | ៤ |
| ពិសភ្លើង ( ស្បែកក្រហម ) | ២១ | ០ | ២១ | ០ | ០ | ០ |
| គ្រុនចាញ់ | ១ | ០ | ១ | ០ | ០ | ០ |
| សាឡាទែន | ០ | ០ | ០ | ០ | ០ | ០ |
| **សរុប** | **១០៤០** | **១១៤** | **១១៥៤** | **៤០២** | **២២** | **៤២៤** |
| **ជម្ងឺផ្នែកសាច់ដុំ និង ឆ្អឹង** | | | | | | |
| ឈឺសាច់ដុំ | ១៣៧ | ៨ | ១៤៥ | ៥៩ | ២ | ៦១ |
| គ្រេច ថ្លោះហើម | ១៨ | ០ | ១៨ | ៣ | ០ | ៣ |
| រលាកសន្លាក់ដៃ-ជើង | ៨៥ | ៥ | ៩០ | ២ | ១ | ៣ |
| ឈឺឆ្អឹងឆ្អែង | ១៤៥ | ៥ | ១៥០ | ៤២ | ០ | ៤២ |
| បាក់ឆឹង | ៣ | ០ | ៣ | ០ | ០ | ០ |
| រលាកសាច់ដុំមានខ្ទុះ | ៤ | ០ | ៤ | ០ | ០ | ០ |
| រលាកឆ្អឹង | ២ | ០ | ២ | ០ | ០ | ០ |
| **សរុប** | **៣៩៤** | **១៨** | **៤១២** | **១០៦** | **៣** | **១០៩** |
| **ជំងឺសសៃប្រសាទ** | | | | | | |
| ជំងឺព្រួយចិត្ត | ៦ | ១ | ៧ | ១ | ០ | ១ |
| ឈឺក្បាល | ២៤៩ | ៦៨ | ៣១៧ | ១១០ | ១០ | ១២០ |
| ឃ្លង់ | ៦ | ០ | ៦ | ០ | ០ | ០ |
| ឈឺតឹងក្នុងក្បាល | ១៣ | ០ | ១៣ | ០ | ០ | ០ |
| រលាកសសៃខួក្បាល | ១០៤ | ៣៤ | ១៣៨ | ៣១ | ០ | ៣១ |
| ជំងឺផ្លូវចិត្ត | ៣ | ០ | ៣ | ០ | ០ | ០ |
| វិលមុខធីងធោង | ១០៣ | ៥ | ១០៨ | ៤៥ | ៤ | ៤៩ |

| | | | | | | |
|---|---|---|---|---|---|---|
| **សរុប** | **៤៨៤** | **១០៨** | **៥៩២** | **១៨៧** | **១៤** | **២០១** |
| **ជំងឺសួត** | | | | | | |
| រលាកសួត | ៨១ | ១៥ | ៩៦ | ៤ | 0 | ៤ |
| រលាកទងសួត | ៨២ | ៧ | ៨៩ | ២៦ | ១ | ២៧ |
| របេងសួត | ៦ | ១ | ៧ | 0 | 0 | 0 |
| ហឺត | ៣២ | 0 | ៣២ | ១ | 0 | ១ |
| **សរុប** | **២០១** | **២៣** | **២២៤** | **៣១** | **១** | **៣២** |
| **ជម្ងឺកង្វះជីវជាតិ** | | | | | | |
| កង្វះវីតាម៉ីន | ២១៣ | ៥៤ | ២៦៧ | ២៥ | ១១ | ៣៦ |
| ខ្វះជាតិស្ករ | ៥ | ២ | ៧ | ១ | ២ | ៣ |
| ទឹកនោមផ្អែម | ១ | 0 | ១ | 0 | 0 | 0 |
| ខ្វះជាតិកាលស្យូម | ៣ | ២ | ៥ | 0 | ២ | ២ |
| ជំងឺស្លឹក | ៤២០ | ៣ | ៤២៣ | ២២ | ២ | ២៤ |
| ជំងឺខ្វះជីវជាតិ អា | ២២ | ១ | ២៣ | ៤ | 0 | ៤ |
| **សរុប** | **៦៦៤** | **៦២** | **៧២៦** | **៥២** | **១៧** | **៦៩** |
| **ជំងឺភ្នែក** | | | | | | |
| ពពែភ្នែក | ៣ | 0 | ៣ | 0 | 0 | 0 |
| រលាកភ្នែក ( ក្រហម) | ៣១ | ២ | ៣៣ | ៩ | 0 | ៩ |
| ទឹកក្នុងគ្រាប់ភ្នែក | ៥ | 0 | ៥ | 0 | 0 | 0 |
| **សរុប** | **៣៩** | **២** | **៤១** | **៩** | **0** | **៩** |
| **ជំងឺកាមរោគ** | | | | | | |
| អេដស៏ | ១៣ | 0 | ១៣ | 0 | 0 | 0 |
| ប្រមេះទឹកបាយ ( នោមខ្ទុះ) | ២២ | 0 | ២២ | ១ | 0 | ១ |
| រលាកជុំវិញក្បាលលិង្គ | ១២ | 0 | ១២ | ១ | 0 | ១ |
| ស្វាយ | 0 | 0 | 0 | ១ | 0 | ១ |
| **សរុប** | **៤៧** | **0** | **៤៧** | **៣** | **0** | **៣** |
| **សរុបទាំងអស់** | **៤៧៦៤** | **៤៨១** | **៥២៤៥** | **១២១៤** | **៩២** | **១៣០៦** |

## ឧបសម្ព័ន្ធ ខ : ឯកសារច្បាប់សិទ្ធិមនុស្សអន្តរជាតិដែលពាក់ព័ន្ធ

### ១- បទបញ្ញត្តិជាបទដ្ឋានអប្បបរមាសំរាប់អនុវត្តចំពោះអ្នកទោស

អនុម័តដោយមហាសន្និបាទអង្គការសហប្រជាជាតិលើកទី ១ ដែលប្រារព្ធធ្វើនៅទីក្រុងហ្សឺណែវក្នុងឆ្នាំ ១៩៥៥ ស្តីពីការការពារឧក្រិដ្ឋជន និងការអនុវត្តន៏ចំពោះជនល្មើសទាំងឡាយ ហើយដែលបានឯកភាព ដោយក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គម ដោយសេចក្តីសំរេចលេខ ៦៦៣ C (XXIV) ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៥៧ និងសេចក្តីសំរេចលេខ ២០៧៦ (LXII) ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ១៩៧៧ ។

ចំពោះអត្ថបទពេញសូមរកតាមអាសយដ្ឋានៈ
http://www.unhchr.ch/html/menu3/b/h_comp35.htm

### ២- គោលការណ៍គ្រឹះសំរាប់អនុវត្តចំពោះអ្នកទោស

អនុម័ត និងប្រកាសដោយមហាសន្និបាទសាមញ្ញ តាមសេចក្តីសំរេចលេខ ៤៥/១១១ ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ១៩៩០ ។

ចំពោះអត្ថបទពេញសូមរកតាមអាសយដ្ឋានៈ
http://www.unhchr.ch/html/menu3/b/h_comp34.htm